សមាគមឧកញ៉ាកម្ពុជា

# ព្រឹត្តិបត្រព័ត៌មានសមាគមឧកញ៉ាកម្ពុជា

## ឆ្នាំទី២ លេខ៨ ត្រីមាសទី៤ ឆ្នាំ២០២៥



ផលិតដោយៈ អគ្គលេខាធិការដ្ឋាន
សមាគមឧកញ៉ាកម្ពុជា

# មាតិកា


- អ្នកឧកញ៉ា សៀ ឬទ្ធី អនុប្រធានសមាគម អមដោយអ្នកឧកញ៉ា គួន ធីតា និងអ្នកឧកញ៉ា ហ៊ុន ឡាក់ ទទួលស្វាគមន៍ និងពិភាក្សាការងារជាមួយលោក Michael Friedl ទីប្រឹក្សាផ្នែកពាណិជ្ជកម្ម នៃស្ថានទូតអូទ្រីស........................................១
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណា **ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** .........................................................២
- អ្នកឧកញ៉ា ផៃ ហុកឈួន អនុប្រធានសមាគម ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា គោរពវិញ្ញាណក្ខន្ធ មហាឧបាសិកា ចាន ឡុញ ដែលជាម្តាយបង្កើតរបស់អ្នកឧកញ៉ា ហឺ បារី សមាជិកក្រុមប្រឹក្សាភិបាល នៃសមាគមឧកញ៉ាកម្ពុជា.............៤
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អាកាសយានដ្ឋានអន្តរជាតិតេជោ ក្រោមអធិបតីភាព **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **លោកជំទាវបណ្ឌិត**,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,៥
- សមាគមឧកញ៉ាកម្ពុជា រៀបចំជំនួបផ្គូផ្គងធុរកិច្ច និងពិសាភោជនាហារដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសមាគមវិនិយោគិនចិនមីននៅកម្ពុជា..........................................................................................................៧
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិកា នៃសមាគមឧកញ៉ាកម្ពុជា ទទួលស្វាគមន៍ និងពិភាក្សាការងារជាមួយ ឯកឧត្តម Andreas Scheuer ប្រធានក្រុមប្រឹក្សាភិបាលស្ថាប័ន Asia Bridge..........................................................................១០
- អ្នកឧកញ៉ា សៀ ឬទ្ធី អនុប្រធានសមាគមឧកញ៉ាកម្ពុជា និងសហការី ទទួលស្វាគមន៍ និងពិភាក្សាការងារជាមួយឯកឧត្តម Vanlalvawna Bawitlung ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា...................................................១២
- អ្នកឧកញ៉ា ផៃ ហុកឈួន អនុប្រធានសមាគម ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា អមដំណើរសម្តេចធិបតីនាយករដ្ឋមន្ត្រី និងលោកជំទាវបណ្ឌិត អញ្ជើញ ចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៧ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធនៅប្រទេសម៉ាឡេស៊ី.......................................................................................................................................១៤
- អ្នកឧកញ៉ា សៀ ឬទ្ធី អនុប្រធានសមាគម ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា អមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងបេសកកម្មទាក់ទាញ និងជំរុញវិនិយោគ នាសហរដ្ឋអាម៉េរិក និងកាណាដា.......................................................................................................................................១៦
- អ្នកឧកញ៉ា ផៃ ហុកឈួន អនុប្រធានសមាគម ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធ នៅវិមានឯករាជ្យ និងថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ.......................................................៣៤
- ថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា បានចូលរួមខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា.......................................................................................................................................៣៦
- អ្នកឧកញ៉ា គួន ធីតា អនុប្រធានសមាគម ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួម «ជំនួបផ្គូផ្គងធុរកិច្ចឥណ្ឌា-កម្ពុជា» .......................................................................................................................................៤០
- អ្នកឧកញ៉ា សៀ ឬទ្ធី អនុប្រធានសមាគម និងជាប្រធានគណៈកម្មការទំនាក់ទំនងសាធារណៈ អន្តរជាតិ និងទេសចរណ៍ ដឹកនាំកិច្ចប្រជុំពិភាក្សាការងារផ្ទៃក្នុង នៃអនុគណៈកម្មការទំនាក់ទំនង និងធុរកិច្ច (អទធ) លើកទី១ ឆ្នាំ២០២៥..........៤១

- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ នៃសមាគមឧកញ៉ាកម្ពុជា ចូលរួម «វេទិកាបង្ហាញសក្តានុពលអាជីវកម្ម និងឧស្សាហកម្មគាំទ្រនៅកម្ពុជា លោកទី១» ក្រោមអធិបតីភាព ឯកឧត្តម ហែម វណ្ណឌី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ និងនវានុវត្តន៍......................................................................................................................................................៤២
- ថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ចូលរួមកម្មវិធី Bridge Reverse & Chateau Angelus Night ដែលត្រូវបានរៀបចំដោយក្រុមហ៊ុន WorldBridge Group ....................................................................................................៤៤
- អ្នកឧកញ៉ា គួន ធីតា អនុប្រធានសមាគម ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីសម្ពោធ «មជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ច និងសហគ្រិនភាពស្ត្រី (ម.ស.ស.ស.) ក្រោមអធិបតីភាព **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** .............................................................................................................................................................៤៦
- ឧកញ៉ា កង លាប សមាជិកក្រុមប្រឹក្សាភិបាល ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីបើក «ពិព័រណ៍ពាណិជ្ជកម្មកម្ពុជាលើកទី១៨ ឆ្នាំ២០២៥» ក្រោមអធិបតីភាព ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា........................................................................................................................................៤៨
- សមាគមឧកញ៉ាកម្ពុជា សហការជាមួយក្រុមហ៊ុន CANCAP GLOBALL រៀបចំកិច្ចពិភាក្សាតុមូលស្តីពី «ការវិនិយោគលើវិស័យកសិកម្ម ប្រព័ន្ធតាមដានសត្វចិញ្ចឹម និងឧស្សាហកម្មឈើកែច្នៃនៅកម្ពុជា» ដោយមានការគាំទ្រពីស្ថានទូតកាណាដាប្រចាំនៅកម្ពុជា...............................................................................................................................................................៥១
- ឧកញ៉ាបណ្ឌិត លីវិទ្ធ សមាជិកក្រុមប្រឹក្សាភិបាលនៃសមាគមឧកញ៉ាកម្ពុជា ចូលរួមកម្មវិធី «បទបង្ហាញផ្នែកឯកជនស្តីពីកម្មវិធីអភិវឌ្ឍន៍បរិវត្តកម្មឌីជីថល និងបញ្ញាសិប្បនិម្មិតកម្ពុជា ឆ្នាំ២០២៦» ..........................................................................៥៣
- អ្នកឧកញ៉ា គួន ធីតា អនុប្រធានសមាគម ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីប្រកួតវគ្គផ្តាច់ព្រ័ត្រ និងបិទវគ្គបណ្តុះបណ្តាលយុវជនក្រោមប្រធានបទ «ជំរុញអានុភាពអនាគតសហគ្រិន» ក្រោមអធិបតីភាព ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា........................៥៤
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ នៃសមាគមឧកញ៉ាកម្ពុជា និងសហការី ចូលរួមជំនួបផ្ទូផ្ទងធុរកិច្ចរវាងសមាគមឧកញ៉ាកម្ពុជា និងស្ថាប័ន Asia Pacific (TOP Excellence) Committee (APC).........................................................................៥៥
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ទទួលជួបសំណេះសំណាល និងពិភាក្សាធុរកិច្ចជាមួយគណៈប្រតិភូធុរកិច្ចឥណ្ឌា នៃសហព័ន្ធអង្គការអ្នកនាំចេញឥណ្ឌា (FIEO)..........................................៥៧
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការសមាគមឧកញ៉ាកម្ពុជា ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួម «ជំនួបផ្ទូផ្ទងធុរកិច្ចកម្ពុជា-ឥណ្ឌា» .......................................................................................................................................................៥៩
- ថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា បំពេញដំណើរទស្សនកិច្ចស្វែងយល់អំពីការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈនៅវិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម (ITI) ...............................................................................៦១
- ឧកញ៉ាបណ្ឌិត តាន់ មុនីវណ្ណ សមាជិកក្រុមប្រឹក្សាភិបាល នៃសមាគមឧកញ៉ាកម្ពុជា និងសហការីបានចូលរួមពិធីបើកសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍វាយតម្លៃលើការអនុវត្តផែនទីបង្ហាញផ្លូវ ការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា ( ផ.អ.យ.អ. ) ក្នុងឆ្នាំ២០២៣-២០២៤...............................................................................................៦៣

# អ្នកឧកញ៉ា សៀ ឬទ្ធី អនុប្រធានសមាគម អមដោយអ្នកឧកញ៉ា គួន ធីតា និងអ្នកឧកញ៉ា ហ៊ុន ឡាក់ ទទួលស្វាគមន៍ និងពិភាក្សាការងារជាមួយលោក Michael Friedl ទីប្រឹក្សាផ្នែកពាណិជ្ជកម្ម នៃស្ថានទូតអូទ្រីស












នាព្រឹកថ្ងៃចន្ទ ៦រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៥ អ្នកឧកញ៉ា សៀ ឬទ្ធី អនុប្រធានសមាគមនិងជាតំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយអ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ក៏ដូចជាអ្នកឧកញ៉ា ហាន់ យាង និងអ្នកឧកញ៉ា គួន ធីតា បានទទួលស្វាគមន៍ និងពិភាក្សាការងារជាមួយលោក Michael Friedl ទីប្រឹក្សាផ្នែកពាណិជ្ជកម្ម នៃស្ថានទូតអូទ្រីស និងជាតំណាងទីភ្នាក់ងារ Advantage Austria ដែលបានប្រព្រឹត្តទៅនៅទីស្នាក់ការសមាគមឧកញ៉ាកម្ពុជា។

ក្នុងឱកាសនេះ អ្នកឧកញ៉ា សៀ ឬទ្ធី បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះលោក Michael Friedl និងក្រុមការងារ និងបានជម្រាបជូនអំពីសាវតា តួនាទីភារកិច្ចស្នូល និងសកម្មភាពសំខាន់ៗរបស់សមាគមដែលជាស្ថាប័នតែមួយគត់ តំណាងឱ្យគោរមវន្តឧកញ៉ាទាំងអស់នៅកម្ពុជា និងជាបណ្តុំធុរជននិងវិនិយោគិនមកពីចម្រុះវិស័យ។អ្នកឧកញ៉ា ក៏បានចែករំលែកអំពីកត្តាទាក់ទាញចម្បងៗ និងសក្តានុពលវិនិយោគនៅកម្ពុជា និងលើកទឹកចិត្តឱ្យក្រុមហ៊ុនអូទ្រីសមកសិក្សាស្វែងយល់ និងបណ្តាក់ទុនវិនិយោគនៅកម្ពុជា ព្រមទាំងរីករាយក្នុងការផ្តល់ការគាំទ្រដល់កិច្ចសហការនានារវាងស្ថាប័នទាំងពីរផងដែរ។

លោក Michael Friedl បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកឧកញ៉ា ដែលបានរៀបចំឱ្យមានកិច្ចប្រជុំមួយនេះឡើង តាមសំណើរបស់លោក និងបានជម្រាបជូនថា ក្រៅពីគោលបំណងនៃជំនួបខាងលើ លោកក៏នឹងរៀបចំបេសកកម្មធុរកិច្ចមកទស្សនកិច្ចនៅកម្ពុជា ក្នុងអំឡុងខែមីនា ឆ្នាំ២០២៦ ខាងមុខនេះ ដែលនឹងមានការចូលរួមពីក្រុមហ៊ុនអូទ្រីសមកពីវិស័យអាទិភាព ដូចជា កសិកម្ម គ្រឿងម៉ាស៊ីនឧស្សាហកម្មនិងវិស្វកម្ម កម្មន្តសាល ប្រព័ន្ធអគ្គីភ័យនិងសុវត្ថិភាព ការប្រឹក្សាយោបល់និងការគ្រប់គ្រងគុណភាព ពាណិជ្ជកម្មអន្តរជាតិនិងការអភិវឌ្ឍ ហិរញ្ញវត្ថុនិងធនាគារ ។ល។ ដើម្បីសិក្សាទីផ្សារ និងស្វែងរកឱកាសវិនិយោគនៅកម្ពុជានាពេលខាងមុខ។

សូមជម្រាបថា Advantage Austria គឺជាទីភ្នាក់ងារផ្លូវការជំរុញអន្តរជាតូបនីយកម្ម និងពាណិជ្ជកម្ម នៃសភាសេដ្ឋកិច្ចសហព័ន្ធអូទ្រីស ដែលជួយបណ្តាក្រុមហ៊ុនអូទ្រីសក្នុងការបង្កើតភាពជាដៃគូធុរកិច្ចនៅក្រៅប្រទេស និងជួយដល់ក្រុមហ៊ុនក្នុងស្រុកទទួលបានជំនាញបច្ចេកវិទ្យា និងការវិនិយោគរបស់អូទ្រីស៕

# លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូ សមាគមឧកញ៉ាកម្ពុជាថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ



នាព្រឹកថ្ងៃពុធ ៨រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៥ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគម ចូលរួមពិធីថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណា ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ នៅមណ្ឌបតម្កល់ព្រះបរមរូបខាងកើតវិមានឯករាជ្យ។

សូមបញ្ជាក់ថា **ព្រះករុណាព្រះបរមរតនកោដ្ឋ** ព្រះរាជប្រសូត្រនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩២២ និងជាព្រះរាជបុត្រា នៃព្រះបាទសម្តេច **ព្រះនរោត្តម សុរាម្រឹត** ព្រះមហាកញ្ញនកោដ្ឋ និងសម្តេចព្រះមហាក្សត្រិយានី **ស៊ីសុវត្ថិ កុសុមៈ នារីរតន៍ សិរីវឌ្ឍនា។** ព្រះអង្គបានលះបង់អស់ព្រះកាយពល និងព្រះរាជបញ្ញាញាណដើម្បីបំពេញព្រះរាជកិច្ចសំខាន់ៗសម្រាប់ប្រជាជាតិខ្មែរដោយបានទាមទារឯករាជ្យពេញលេញជូនជាតិមាតុភូមិពីអាណានិគមបារាំងព្រមទាំងបានកសាងនូវហេដ្ឋារចនាសម្ព័ន្ធក៏ដូចជាដឹកនាំព្រះរាជាណាចក្រកម្ពុជាឆ្ពោះទៅកាន់ភាពរីកចម្រើនគ្រប់វិស័យ។

**ព្រះមហាវីរក្សត្រ** បានសោយទិវង្គតនាថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ នារដ្ឋធានីប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិនហើយត្រូវបានដង្ហែព្រះបរមសពមកកាន់ព្រះរាជាណាចក្រកម្ពុជាដើម្បីប្រារព្ធព្រះរាជពិធីថ្វាយព្រះភ្លើងតាមព្រះរាជបវេណីប្រកបដោយក្តីទុក្ខសោកសង្រេងរបស់ប្រជាជនខ្មែរនៅទូទាំងប្រទេស។

ទូលបង្គំនិងខ្ញុំម្ចាស់ទាំងអស់គ្នា សូមក្រាបបង្គំថ្វាយព្រះរាជកុសល និងសូមថ្វាយព្រះរាជកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត និងសូមចងចាំជានិច្ចនូវគុណូបការៈដ៏មានតម្លៃមិនអាចកាត់ថ្លៃបានដែលព្រះអង្គបានបន្សល់ទុកសម្រាប់ប្រជាជាតិខ្មែរជាទីស្រលាញ់របស់ព្រះអង្គ៕














# អ្នកឧកញ៉ា ផៃ ហុកឈួន អនុប្រធានសមាគម ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា គោរពវិញ្ញាណក្ខន្ធមហាឧបាសិកា ចាន ឡុញ ដែលជាម្ដាយបង្កើតរបស់អ្នកឧកញ៉ា ហ៊ី បាវី សមាជិកក្រុមប្រឹក្សាភិបាល នៃសមាគមឧកញ៉ាកម្ពុជា

នាថ្ងៃព្រហស្បតិ៍ ៩រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៥ អ្នកឧកញ៉ា ផៃ ហុកឈួន អនុប្រធានសមាគមឧកញ៉ាកម្ពុជា តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា អមដោយអគ្គលេខាធិការ រួមទាំងអ្នកឧកញ៉ា ឧកញ៉ា ជាអនុប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាល ក៏ដូចជាសមាជិកសមាគមជាច្រើនរូបទៀត បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសព មហាឧបាសិកា ចាន ឡុញ ដែលត្រូវជាម្ដាយក្មេករបស់ អ្នកឧកញ៉ា ហ៊ី បាវី សមាជិកក្រុមប្រឹក្សាភិបាល នៃសមាគមឧកញ៉ាកម្ពុជា និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ។

មរណភាពរបស់ មហាឧបាសិកា ចាន ឡុញ គឺជាការបាត់បង់យ៉ាងធំធេងនូវម្ដាយបង្កើត ម្ដាយក្មេក និងជីដូនប្រកបដោយព្រហ្មវិហារធម៌ និងជាទីគោរពស្រលាញ់បំផុតរបស់ក្រុមគ្រួសារ ដែលបានចិញ្ចឹមបីបាច់ថែរក្សា និងអប់រំទូន្មានកូនចៅរហូតក្លាយជាធនធានមនុស្សដែលបាននិងកំពុងចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គមជាតិនាពេលបច្ចុប្បន្ន។

ស្ថិតក្នុងបរិយាកាសដ៏សែនក្រៀមក្រំនេះ យើងខ្ញុំសូមចូលរួមរំលែកមរណទុក្ខដោយក្ដីស្រណោះ និងអាឡោះអាល័យបំផុតជាមួយក្រុមគ្រួសារនៃសព និងសូមបួងសួងដល់ដួងវិញ្ញាណក្ខន្ធរបស់ មហាឧបាសិកា ចាន ឡុញ បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ៕













# លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអាកាសយានដ្ឋានអន្តរជាតិតេជោ ក្រោមអធិបតីភាពសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត និងលោកជំទាវបណ្ឌិត




នាថ្ងៃចន្ទ ១៣រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៥ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអាកាស យានដ្ឋានអន្តរជាតិតេជោ (TECHO INTERNATIONAL AIRPORT) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត**។

ជាការពិតណាស់  អាកាសយានដ្ឋានអន្តរជាតិតេជោ  គឺជាសមិទ្ធផលថ្មីមួយទៀតដែលជាការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋាន និងតភ្ជាប់ជើងហោះហើរទៅកាន់ពិភពលោកកាន់តែធំ និងទូលាយជាងមុន ព្រមទាំងជានិម្មិតរូបនៃការរីកចម្រើនរបស់ព្រះរាជាណាចក្រកម្ពុជា ដែលកើតចេញពីគំនិតផ្តួចផ្តើមប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋ មន្ត្រី  បច្ចុប្បន្នជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលនឹងក្លាយជាកម្លាំងចលករដ៏សំខាន់ជំរុញកំណើនសេដ្ឋកិច្ចជាតិ លើកស្ទួយវិស័យអាកាសចរណ៍ ទេសចរណ៍ វិនិយោគ វិស័យដឹកជញ្ជូន និងឡូជីស្ទីក (Logistic) របស់កម្ពុជា។








សូមបញ្ជាក់ថា អាកាសយានដ្ឋានអន្តរជាតិតេជោ ជាអាកាសយានដ្ឋានលំដាប់ថ្នាក់ 4F រួមទាំងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ត្រូវបានចំណាយទុនវិនិយោគសរុប ២,៣០០ លានដុល្លារអាម៉េរិក និងបានសាងសង់នៅលើផ្ទៃដីសរុបទំហំ ២,៦០០ ហិកតា ដោយចំណាយពេលសាងសង់ចំនួនជាង ៥ឆ្នាំដែលបានចាប់ផ្តើមនៅថ្ងៃទី៧ ខែមករា ឆ្នាំ២០២០ និងបញ្ចប់នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥។ អាកាសយានដ្ឋាននេះ មានហេដ្ឋារចនាសម្ព័ន្ធគ្រប់លក្ខខណ្ឌតាមស្តង់ដាអន្តរជាតិ ដែលអាចបម្រើការហោះហើរបានដល់យន្តហោះគ្រប់ប្រភេទទាំងជើងហោះហើរក្នុងតំបន់ និងជើងហោះហើររយៈចម្ងាយឆ្ងាយ (Long-haul Flights) ដែលអាចចុះចតបានដោយសុវត្ថិភាព។ ការសាងសង់អាកាសយានដ្ឋាននេះ ត្រូវបានបែងចែកជា៣ដំណាក់កាលគឺ៖ ដំណាក់កាលទី១ ពីឆ្នាំ២០២០ ដល់២០៣០ ដែលអាចទទួលអ្នកដំណើរ១៥លាននាក់ក្នុងមួយឆ្នាំ។ ដំណាក់កាលទី២ ពីឆ្នាំ២០៣០ ដល់ឆ្នាំ២០៥០ ដែលអាចទទួលអ្នកដំណើរចំនួន៣០លាននាក់ក្នុង១ឆ្នាំ និងដំណាក់កាលទី៣ ក្រោយឆ្នាំ២០៥០ សម្រាប់ទទួលអ្នកដំណើរ ៥០លាននាក់ក្នុងមួយឆ្នាំ។





















# សមាគមឧកញ៉ាកម្ពុជា រៀបចំជំនួបផ្គូផ្គងធុរកិច្ច និងពិសាភោជនាហារ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយសមាគមវិនិយោគិនចិនមីននៅកម្ពុជា




នាថ្ងៃចន្ទ ១៣រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៥ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា អមដោយ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ជាថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា បានទទួលស្វាគមន៍ លោក លីន ស៊ានរ៉ុង ប្រធានសមាគមវិនិយោគិនចិនមីននៅកម្ពុជា ក្នុង «ជំនួបផ្គូផ្គងធុរកិច្ច និងពិសាភោជនាហារ» ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ ក៏ដូចជាផ្តល់នូវកាលានុវត្តភាពសម្រាប់ការផ្គូផ្គង និងពិភាក្សាធុរកិច្ចរវាងសមាជិក នៃសមាគមទាំងពីរ។

មុននឹងចាប់ផ្តើម អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ បានរំលេចពីសារៈតារនៃកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងរវាងសមាគមទាំងពីរដើម្បីឈានទៅរកការរៀបចំជំនួបផ្សេងៗជាបន្តបន្ទាប់ទៀតទៅតាមវិស័យដែលមានសក្តានុពលរបស់សមាជិក នៃសមាគមទាំងពីរ។



ជាកិច្ចចាប់ផ្តើម អ្នកឧកញ៉ា គួន ធីតា អនុប្រធាន និងជាប្រធានអនុគណៈកម្មការទំនាក់ទំនង និងធុរកិច្ច បានថ្លែងសុន្ទរកថា ស្វាគមន៍គណៈប្រតិភូសមាគមវិនិយោគិនចិនមីននៅកម្ពុជាដែលបានផ្តល់កិត្តិយសចូលរួមក្នុងពិធីដ៏មានសារៈសំខាន់នេះ ដោយអ្នកឧកញ៉ាបានគូសបញ្ជាក់នូវការកកើត នៃទំនាក់ទំនងជាដៃគូរវាងស្ថាប័នទាំងពីរតាមរយៈ ដំណើរទស្សនកិច្ចផ្លូវការទៅកាន់ទីក្រុងសៀមិន ខេត្តហ្វ៊ូជៀន នៃសាធារណរដ្ឋប្រជាមានិតចិន នាអំឡុងខែកញ្ញាកន្លងមក ក្នុងបេសកកម្មជំរុញ និងទាក់ទាញវិនិយោគ ដែលដឹកនាំដោយ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយគណៈប្រតិភូកម្ពុជា ទទួលបាននូវការបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅពីសំណាក់ថ្នាក់ដឹកនាំនៃសមាគមវិនិយោគិនចិនមីន ព្រមទាំងមានរៀបចំនូវពិធីស្វាគមន៍ និងជំនួបធុរកិច្ច ជាពិសេសសម្រេចបាននូវការចុះអនុស្សរណៈនៃការយោគយល់គ្នារវាងសមាគមទាំងពីរកាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៥ ក្រោមអធិបតីភាព ឯកឧត្តម ស៊ុន ចាន់ថុល ផងដែរ។ ហេតុនេះហើយ ទើបលោកអ្នកឧកញ៉ា លី យ៉ុងផាត់ បានស្នើឱ្យមានការរៀបចំពិធីនាថ្ងៃនេះដើម្បីជាកិច្ចស្វាគមន៍ចំពោះគណៈប្រតិភូ នៃសមាគមវិនិយោគិនចិនមីន ក្នុងដំណើរទស្សនកិច្ចមកកាន់រាជធានីភ្នំពេញវិញម្តង ក្នុងគោលបំណងបន្តកិច្ចសហប្រតិបត្តិការគ្នាឱ្យកាន់តែស្អិតរមួតបន្ថែមទៀត។



ទន្ទឹមនឹងនេះ លោក លីន ស៊ាន់រ៉ុង បានថ្លែងថា លោក និងសហការីមានក្ដីរំភើបយ៉ាងខ្លាំង និងសូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ នៃសមាគមឧកញ៉ាកម្ពុជា ដែលបានខិតខំខ្នះខ្នែងក្នុងការបង្កើត និងពង្រឹងកិច្ចសហការរវាងស្ថាប័នទាំងពីរ ហើយលោកមានសុទិដ្ឋិនិយមថា តាមរយៈកម្មវិធីនៅថ្ងៃនេះ នឹងក្លាយជាឱកាសដ៏មានអត្ថប្រយោជន៍ដល់សមាជិកទាំងអស់អាចប្រាស្រ័យទាក់ទង និងស្វែងយល់ពីគ្នាទៅវិញទៅមកដើម្បីឈានទៅរកការចាប់ដៃសហការគ្នាក្នុងសកម្មភាពពាណិជ្ជកម្មណាមួយដែលនឹងផ្ដល់ផលដល់សមាជិកនៃស្ថាប័នទាំងសងខាងក៏ដូចជាសម្រាប់សេដ្ឋកិច្ចកម្ពុជាផងដែរ។



ក្នុងឱកាសដ៏វិសេសវិសាលនេះដែរ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានផ្ដល់កិត្តិយសថ្លែងសុន្ទរកថាបើកអង្គពិធីជាផ្លូវការ ដោយបានសង្កត់ធ្ងន់ថាកម្មវិធីនេះនឹងក្លាយជានិមិត្តរូបនៃការចងចាំ និងការបន្តកិច្ចសហប្រតិបត្តិការដ៏យូរអង្វែងព្រមទាំងនាំមកនូវភាពជោគជ័យ និងការរីកចម្រើនទាំងអស់គ្នា។ លោកអ្នកឧកញ៉ា មានក្ដីសង្ឃឹមថា តាមរយៈភាពជាដៃគូនៃសមាគមទាំងពីរនឹងបើកឱកាសដល់សមាជិកទាំងអស់អាចប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកកាន់តែជិតស្និទ្ធលើសកម្មភាពធុរកិច្ច ពាណិជ្ជកម្ម និងការវិនិយោគបន្ថែមទៀតជាក់ជាមិនខាន។

សូមបញ្ជាក់ថា ស្របតាមអនុស្សរណៈនៃការយោគយល់គ្នា សមាគមទាំងពីរបានឯកភាពពង្រឹងការវិនិយោគទ្វេភាគី សម្របសម្រួលការផ្លាស់ប្ដូរសកម្មភាពសេដ្ឋកិច្ចនិងពាណិជ្ជកម្ម និលើកកម្ពស់កាលានុវត្តភាព និងបរិយាកាសធុរកិច្ចរវាងកម្ពុជានិងចិន ដោយផ្ដោតលើកិច្ចសហប្រត្តិការលើ៣ចំណុចសំខាន់ៗគឺៈ

១)ការលើកកម្ពស់ធុរកិច្ច និងវិនិយោគ

២)ការផ្លាស់ប្ដូរពាណិជ្ជកម្ម និងការផ្គូផ្គងធុរកិច្ច និង

៣)ការផ្លាស់ប្ដូរចំណេះដឹង និងការកសាងសមត្ថភាព។























"柬埔寨勋爵协会与柬埔寨中国闽商会 商务对接与联谊晚宴"
2025 年 10 月 20 日

# អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ នៃសមាគមឧកញ៉ាកម្ពុជា ទទួលស្វាគមន៍និងពិភាក្សាការងារជាមួយ ឯកឧត្តម Andreas Scheuer ប្រធានក្រុមប្រឹក្សាភិបាលស្ថាប័ន Asia Bridge

នាព្រឹកថ្ងៃពុធ ទី២២ ខែតុលា ឆ្នាំ២០២៥នេះ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានជួបពិភាក្សាការងារជាមួយ ឯកឧត្តម Andreas Scheuer ប្រធានក្រុមប្រឹក្សាភិបាលស្ថាប័ន Asia Bridge និងជាអតីតរដ្ឋមន្ត្រីសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ទទួលបន្ទុកវិស័យដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដែលប្រព្រឹត្តទៅនៅទីស្នាក់ការសមាគមឧកញ៉ាកម្ពុជា ក្នុងឱកាសដែលឯកឧត្តមកំពុងបំពេញបេសកកម្មនៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងកិច្ចពិភាក្សាប្រកបដោយភាពស្និទ្ធស្នាលនេះ អ្នកឧកញ៉ា និងឯកឧត្តមប្រធានក្រុមប្រឹក្សាភិបាល បានពិភាក្សាផ្លាស់ប្តូរយោបល់គ្នាពាក់ព័ន្ធនឹងបទពិសោធន៍ការងារកន្លងមក ក៏ដូចជាបរិយាកាសវិនិយោគនៅកម្ពុជា, ពិពិធកម្មសេដ្ឋកិច្ច និងគោលដៅវិនិយោគ, ពាណិជ្ជកម្មអន្តរជាតិ, ការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធ, បច្ចេកវិទ្យាឌីជីថល និងកាលានុវត្តភាពនៃកិច្ចសហប្រតិបត្តិការធុរកិច្ច និងភាពជាដៃគូរវាងស្ថាប័នទាំងពីរខណៈដែលការពង្រឹងទំនាក់ទំនង និងស្វែងរកកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសនៅអាស៊ីរួមទាំងកម្ពុជាគឺជាគោលដៅលេចធ្លោមួយដែល Asia Bridge កំពុងចាប់អារម្មណ៍។

លើសពីនេះ អ្នកឧកញ៉ាអគ្គលេខាធិការ ក៏បានជម្រាបជូនបន្ថែមអំពីសាវតា តួនាទី និងភារកិច្ចស្នូលរបស់សមាគមដែលជាស្ថាប័នតែមួយគត់ តំណាងឱ្យគោរមវន្តឧកញ៉ាទាំងអស់នៅកម្ពុជា និងជាបណ្តុំធុរជននិងវិនិយោគិនមកពីចម្រុះវិស័យ។ អ្នកឧកញ៉ា បានលើកទឹកចិត្តឱ្យក្រុមហ៊ុនអាល្លឺម៉ង់មកសិក្សាស្វែងយល់ និងបណ្តាក់ទុនវិនិយោគនៅកម្ពុជា ព្រមទាំងរីករាយក្នុងការផ្តល់ការគាំទ្រដល់កិច្ចសហការនានារវាងស្ថាប័នទាំងពីរផងដែរ។






















ជាមួយគ្នានេះ ឯកឧត្តមប្រធានក្រុមប្រឹក្សាភិបាល បានសម្តែងនូវការកត់សម្គាល់ខ្ពស់ចំពោះកំណែទម្រង់នានាដែលនាំឱ្យកម្ពុជាមានការផ្លាស់ប្តូរមុខមាត់ក្នុងរយៈពេលចុងក្រោយ ព្រមទាំងបានសម្តែងនូវការកោតសសើរខ្ពស់ចំពោះសមាគមឧកញ៉ាកម្ពុជា ក្នុងការរួមចំណែកលើកកម្ពស់សកម្មភាពពាណិជ្ជកម្ម និងសេដ្ឋកិច្ចកម្ពុជា។ ឯកឧត្តមប្រធាន បានបង្ហាញនូវការតាំងចិត្តក្នុងការពាំនាំអំពីចំនុចវិជ្ជមាន និងសក្តានុពលនានារបស់កម្ពុជាដែលលោកបានស្វែងយល់ក្នុងទស្សនកិច្ចនេះ ទៅផ្សព្វផ្សាយបន្តនៅក្នុងសហគមន៍ធុរកិច្ច និងពាណិជ្ជកម្ម ដែលមានទំនាក់ទំនងជាមួយស្ថាប័ន Asia Bridge ផងដែរ។

តាមការពិភាក្សាផ្លាស់ប្តូរយោបល់នាឱកាសនេះ អ្នកឧកញ៉ា និង ឯកឧត្តមប្រធានក្រុមប្រឹក្សាភិបាល បានឯកភាពបន្តពិភាក្សាដើម្បីកសាងស្ពានតភ្ជាប់ទំនាក់ទំនងគ្នា និងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរដើម្បីរៀបចំជំនួបផ្គូរផ្គងធុរកិច្ចនៅពេលអនាគតខាងមុខ។

សូមជម្រាបដែរថា Asia Bridge មានឈ្មោះពេញជាផ្លូវការគឺ “Asienbrücke e.V. – Euro-Asian-Initiative” ត្រូវបានបង្កើតឡើងនៅទីក្រុងប៉ែរឡាំង ប្រទេសអាល្លឺម៉ង់ ក្នុងខែកញ្ញា ឆ្នាំ២០១៩ ជាមួយគោលដៅចម្បងផ្តោតលើការពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសអាល្លឺម៉ង់ (និងសហភាពអឺរ៉ុប) ជាមួយតំបន់អាស៊ីប៉ាស៊ីហ្វិក៕

# អ្នកឧកញ៉ា សៀ ឬទ្ធី អនុប្រធានសមាគមឧកញ៉ាកម្ពុជា និងសហការី ទទួលស្វាគមន៍និងពិភាក្សាការងារជាមួយឯកឧត្តម Vanlalvawna Bawitlung ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា



អ្នកឧកញ៉ា សៀ ឬទ្ធី អនុប្រធាន តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា អមដោយ អនុប្រធាន អគ្គលេខាធិការ សមាជិកក្រុមប្រឹក្សាភិបាល និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា បានជួបពិភាក្សាការងារជាមួយ ឯកឧត្តម Vanlalvawna Bawitlung ឯកអគ្គរដ្ឋទូតឥណ្ឌា ប្រចាំព្រះរាជាណាចក្រកម្ពុជា និងសហការីដែលប្រព្រឹត្តទៅនៅទីស្នាក់ការសមាគមឧកញ៉ាកម្ពុជា កាលពីព្រឹកថ្ងៃពុធ ទី២២ ខែតុលា ឆ្នាំ២០២៥ ក្នុងគោលបំណងពិភាក្សាការងារលើការពង្រឹងទំនាក់ទំនងល្អ និងពិភាក្សាលើការជំរុញកិច្ចសហប្រតិបត្តិការធុរកិច្ច និងសកម្មភាពពាណិជ្ជកម្មកម្ពុជា-ឥណ្ឌា ឱ្យកាន់តែមានភាពសកម្ម និងកាន់តែប្រសើរមួយកម្រិតថែមទៀត។

ជាកិច្ចចាប់ផ្តើម អ្នកឧកញ៉ា បានសម្តែងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះ ឯកឧត្តមឯកអគ្គរដ្ឋទូត និងសហការី និងបានប្រគល់តួនាទីជូន អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ជម្រាបជូនអំពីសាវតារ តួនាទីភារកិច្ចស្នូល និងសកម្មភាពសំខាន់ៗរបស់សមាគមដែលជាស្ថាប័នតែមួយគត់ តំណាងឱ្យគោរមវន្តឧកញ៉ាទាំងអស់នៅកម្ពុជា និងមានសមាជិកប្រកបដោយសក្តានុពលជាបណ្តុំធុរជននិងវិនិយោគិនធ្វើការវិនិយោគលើចម្រុះវិស័យ។ បន្ថែមលើនេះ អ្នកឧកញ៉ាបានលើកឡើងអំពីទំនាក់ទំនងធុរកិច្ច និងការវិនិយោគរវាងកម្ពុជានិងឥណ្ឌា ដែលនាពេលកន្លងមកមានសកម្មភាពតែទៅលើវិស័យអប់រំ ទេសចរណ៍ សុខាភិបាល និងវប្បធម៌ ហើយសកម្មភាពធុរកិច្ចក្នុងវិស័យទាំងនេះមានកម្រិតមួយទាបនៅឡើយ។ អ្នកឧកញ៉ាមើលឃើញឥណ្ឌាជាប្រទេសមួយពោរពេញសក្តានុពលលើគ្រប់វិស័យ និងជាទីផ្សារដ៏ធំមួយជាមួយសេដ្ឋកិច្ចលូតលាស់លឿនបំផុតក្នុងពិភពលោក។ ហេតុដូច្នេះ អ្នកឧកញ៉ាយល់ឃើញថា ប្រទេសទាំងពីរអាចធ្វើអ្វីបានច្រើនលើសពីនេះ តាមរយៈការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការធុរកិច្ច និងវិនិយោគដែលមានស្រាប់ឱ្យឈានខ្ពស់មួយកម្រិតទៀត និងចាប់ផ្តើមជំរុញវិស័យអាទិភាពផ្សេងទៀតដែលជាតម្រូវការទីផ្សារនៃប្រទេសទាំងពីរ ដូចជា កសិ-ឧស្សាហកម្ម អាហារនិងភេសជ្ជៈ បដិសណ្ឋារកិច្ច បច្ចេកវិទ្យា និងបច្ចេកវិទ្យាព័ត៌មាន ជាដើម។

ជាកិច្ចឆ្លើយតប ឯកឧត្តមឯកអគ្គរដ្ឋទូត បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅសម្រាប់ការរៀបចំឱ្យមានជំនួបនាថ្ងៃនេះ និងគាំទ្រចំពោះការចែករំលែករបស់អ្នកឧកញ៉ា ពាក់ព័ន្ធនឹងការជំរុញទំនាក់ទំនងធុរកិច្ច សកម្មភាពពាណិជ្ជកម្ម និងការវិនិយោគរវាងប្រទេសទាំងពីរ។ ឯកឧត្តមឯកអគ្គរដ្ឋទូត បានបង្ហាញការយល់ស្របថា ការផ្លាស់ប្តូរពាណិជ្ជកម្ម និងការវិនិយោគរវាងកម្ពុជានិងឥណ្ឌា គឺពិតជានៅមានកម្រិតនៅឡើយ ដែលត្រូវមានចំណាត់ការក្នុងការជំរុញឱ្យមានភាពល្អប្រសើរជាងនេះ។ ហេតុដូច្នេះ ឯកឧត្តមឯកអគ្គរដ្ឋទូត ពិតជាត្រូវការភាពជាដៃគូរវាងស្ថានទូត និងសមាគមក្នុងការរៀបចំឱ្យមានព្រឹត្តិការធុរកិច្ចនានា ដូចជា វេទិកាធុរកិច្ច បេសកកម្មជំរុញនិងទាក់ទាញវិនិយោគ ការផ្លាស់ប្តូរទស្សនកិច្ចធុរកិច្ច សិក្ខាសាលា និងការផ្គូផ្គងធុរកិច្ច ជាដើម ដើម្បីជំរុញសកម្មភាពពាណិជ្ជកម្ម និងការវិនិយោគរវាងប្រទេសទាំងពីរ។ លើសពីនេះ ឯកឧត្តមឯកអគ្គរដ្ឋទូត ក៏នឹងផ្សព្វផ្សាយអំពីចំណុចវិជ្ជមាន និងសក្តានុពលនានារបស់កម្ពុជា ព្រមទាំងកៀរគរវិនិយោគិនឥណ្ឌាឱ្យមកសិក្សាស្វែងយល់ និងបណ្តាក់ទុនវិនិយោគនៅកម្ពុជាឱ្យកាន់តែច្រើនថែមទៀត។

បន្ទាប់ពីកិច្ចពិភាក្សាផ្លាស់ប្តូរយោបល់ប្រកបដោយភាពស្និទ្ធស្នាល អ្នកឧកញ៉ា និង ឯកឧត្តមឯកអគ្គរដ្ឋទូត បានបង្ហាញក្តីរីករាយ និងផ្តល់ការគាំទ្រទៅវិញទៅមកលើកិច្ចសហប្រតិបត្តិការរវាងស្ថានទូត និងសមាគមក្នុងការជំរុញទំនាក់ទំនងធុរកិច្ច សកម្មភាពពាណិជ្ជកម្ម និងការវិនិយោគ រវាងកម្ពុជា និងឥណ្ឌា ឱ្យកាន់តែប្រសើរឡើងនាពេលអនាគត។ សូមជម្រាបដែរថា សមាគមឧកញ៉ាកម្ពុជា និងសហព័ន្ធសភាពាណិជ្ជកម្ម និងឧស្សាហកម្មឥណ្ឌា បានសម្រេចចាប់ផ្តើមជាផ្លូវការនូវក្រុមប្រឹក្សាធុរកិច្ចរួមគ្នារវាងឥណ្ឌា-កម្ពុជា ឬ the India-Cambodia Joint Business Council (ICJBC) តាមរយៈពិធីសម្ពោធនាថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រោមអធិបតីភាពថ្នាក់ដឹកនាំនៃក្រសួងពាណិជ្ជកម្មកម្ពុជា ក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មឥណ្ឌា ព្រមទាំងកិច្ចសម្របសម្រួលនៃនាយកដ្ឋានជំរុញឧស្សាហកម្ម និងពាណិជ្ជកម្មផ្ទៃក្នុងប្រទេស ( DPIIT)។ ក្រុមប្រឹក្សានេះ ត្រូវបានបង្កើតឡើងក្នុងគោលដៅជំរុញសកម្មភាពពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសឥណ្ឌា-កម្ពុជា តាមរយៈកិច្ចពិភាក្សា និងកិច្ចសហប្រតិបត្តិការ រវាងវិស័យឯកជននៃប្រទេសទាំងពីរ។












# អ្នកឧកញ៉ា ផៃ ហុកឈួន ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា អមដំណើរ សម្តេចធិបតីនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិតអញ្ជើញ ចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៧និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ នៅប្រទេសម៉ាឡេស៊ី



ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី**, លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានចាត់តាំង អ្នកឧកញ៉ា ផៃ ហុកឈួន អនុប្រធាន និងជាប្រធានគណៈកម្មការរដ្ឋបាល ហិរញ្ញវត្ថុ និងធនាគារ ដើម្បីដឹកនាំគណៈប្រតិភូ នៃសមាគមឧកញ៉ាកម្ពុជាដែលរួមមាន អ្នកឧកញ៉ា ហាន់ យាង, អ្នកឧកញ៉ា ហេង ឡុង, អ្នកឧកញ៉ា សុខ ឆេង, អ្នកឧកញ៉ា ហ៊ុន ឡាក់ ព្រមទាំង លោក ម៉ៅ សុទ្ធីវឌ្ឍ អមដំណើរ **សម្តេចមហាបវរធិបតី** និង **លោកជំទាវបណ្ឌិត** អញ្ជើញចូលរួមកិច្ចប្រជុំកំពូល

អាស៊ានលើកទី៤៧និងកិច្ចប្រជុំកំពូលពាក់ព័ន្ធដែលបានប្រព្រឹត្តទៅនៅទីក្រុងគូឡាឡាំពួប្រទេសម៉ាឡេស៊ីចាប់ពីថ្ងៃទី២៥-២៨ខែតុលាឆ្នាំ២០២៥ ដោយគណៈប្រតិភូបានចេញដំណើរនារសៀលថ្ងៃទី២៥ ខែតុលា។

ក្នុងអំឡុងពេលអមដំណើរប្រមុខថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា បានចូលរួមជំនួប និងកម្មវិធីមួយចំនួនជាបន្តបន្ទាប់ដូចជា៖

១. ចូលរួមព្រឹត្តិការណ៍ ASEAN Business & Investment Summit 2025 ដែលត្រូវបានរៀបចំឡើងនៅមជ្ឈមណ្ឌលពិព័រណ៍ និងពាណិជ្ជកម្មអន្តរជាតិម៉ាឡេស៊ី ឬ Malaysia International Trade and Exhibition Centre (MITEC) ។

២. ចូលរួមជាមួយអ្នកឧកញ៉ា គិត ម៉េង ប្រធានសភាពាណិជ្ជកម្មកម្ពុជា និងជាប្រធានក្រុមប្រឹក្សាពិគ្រោះយោបល់ធុរកិច្ចអាស៊ានសម្រាប់កម្ពុជា ក្នុងជំនួបជាមួយក្រុមប្រឹក្សាធុរកិច្ចកាណាដា-អាស៊ាន ដែលដឹកនាំដោយ លោក Wayne C. Farmer ។

៣. ចូលរួមជាមួយអ្នកឧកញ៉ា គិត ម៉េង ប្រធានសភាពាណិជ្ជកម្មកម្ពុជា និងជាប្រធានក្រុមប្រឹក្សាពិគ្រោះយោបល់ធុរកិច្ចអាស៊ានសម្រាប់កម្ពុជា រួមទាំងសមាជិកសភាពាណិជ្ជកម្ម ក្នុងជំនួបជាមួយក្រុមប្រឹក្សាធុរកិច្ចអង់គ្លេស-អាស៊ាន ដឹកនាំដោយលោក Lord Vaizey ។

៤ . ចូលរួមជាមួយ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងជំនួបសំណេះសំណាល និងធ្វើជាសាក្សីក្នុងពិធីចុះអនុស្សរណៈ នៃការយោគយល់គ្នាលើគម្រោងវិនិយោគចិញ្ចឹមគោ និងផលិតទឹកដោះគោនៅកម្ពុជា រវាងក្រុមហ៊ុន Farm Fresh Group របស់ម៉ាឡេស៊ី និងក្រុមហ៊ុន Alpha group របស់ អ្នកឧកញ៉ា លី យុនថៃ ដែលជាប្រធានក្រុមប្រឹក្សាភិបាល និងជាសមាជិកនៃសមាគមឧកញ៉ាកម្ពុជា ។

៥. ចូលរួមជាមួយអ្នកឧកញ៉ា គិត ម៉េង ប្រធានសភាពាណិជ្ជកម្មកម្ពុជា និងជាប្រធានក្រុមប្រឹក្សាពិគ្រោះយោបល់ធុរកិច្ចអាស៊ានសម្រាប់កម្ពុជា រួមទាំងសមាជិកសភាពាណិជ្ជកម្មកម្ពុជា ក្នុងវេទិកាអាស៊ាន អ៊ិនឌូឆាយណា ប៉ាស៊ីហ្វិក ហៅកាត់ថា ( AIPF ) ASEAN-Indo Pacific Forum ។

៦. ចូលរួមជាមួយអ្នកឧកញ៉ា គិត ម៉េង ប្រធានសភាពាណិជ្ជកម្មកម្ពុជា និងជាប្រធានក្រុមប្រឹក្សាពិគ្រោះយោបល់ធុរកិច្ចអាស៊ានសម្រាប់កម្ពុជា រួមទាំងសមាជិកសភាពាណិជ្ជកម្ម ក្នុងជំនួបជាមួយ Datuk Ng Yih Pyng ប្រធានសភាពាណិជ្ជកម្ម និងឧស្សាហកម្មចិន នៅម៉ាឡេស៊ី (ACCCIM) ដើម្បីសម្ដែងការគួរសម និងពិភាក្សាការងារ។

៧. ចូលរួមជាមួយសភាពាណិជ្ជកម្មកម្ពុជា ក្នុងដំណើរទស្សនកិច្ច មជ្ឈមណ្ឌលបច្ចេកវិទ្យា និងនវានុវត្តន៍ របស់ក្រុមហ៊ុនហួវ៉េ (Huawei) នៅប្រទេសម៉ាឡេស៊ី ។

បន្ទាប់ពីបានបំពេញបេសកកម្មប្រកបដោយជោគជ័យរួចមក គណៈប្រតិភូ នៃសមាគមឧកញ៉ាកម្ពុជា បានមាតុភូមិនិវត្តន៍វិញនាល្ងាចថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៥ ប្រកបដោយសុវត្ថិភាព។



















# អ្នកឧកញ៉ា សៀ ឬទ្ធី ដឹកនាំ គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា អមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងបេសកកម្មទាក់ទាញ និងជំរុញវិនិយោគ នាសហរដ្ឋអាមេរិក និងប្រទេសកាណាដា

យោងតាមសំណើពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានចាត់តាំង អ្នកឧកញ៉ា សៀ ឬទ្ធី អនុប្រធាន និងជាប្រធានគណៈកម្មការទំនាក់ទំនងសាធារណៈ អន្តរជាតិ និងទេសចរណ៍ ធ្វើជាតំណាងដើម្បីដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជារួមមាន អ្នកឧកញ៉ា លី សុភាព, អ្នកឧកញ៉ាសួរ វីរៈ, ឧកញ៉ា លីម តារារិទ្ធ និង លោក អ៊ឹង វីរៈ អមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងបេសកកម្មទាក់ទាញ និងជំរុញវិនិយោគទៅកាន់សហរដ្ឋអាមេរិក និងប្រទេសកាណាដា ចាប់ពីថ្ងៃទី២៧ ខែតុលា ដល់ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៥។

សូមបញ្ជាក់ថា គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាបានបំពេញបេសកកម្មនៅក្នុងទីក្រុងឡូសអែនជឺឡេស, ឈីកាហ្គោ និងរដ្ឋធានីវ៉ាស៊ីនតោន នៃសហរដ្ឋអាមេរិក ដោយបានចូលរួមក្នុងកម្មវិធីសំខាន់ៗជាច្រើនរួមមាន៖

១. ចូលរួមក្នុង «វេទិកាភាពជាដៃគូពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងកម្ពុជា» ដែលបានប្រារព្ធឡើងនៅ California State University, Long Beach (CSULB) នៅទីក្រុងឡុងប៊ិច ដែលមានការចូលរួមពីតំណាងក្រុមហ៊ុនចំនួន ៧៥ មកពីពហុវិស័យ។ វេទិកានេះនាំមកនូវការលើកកម្ពស់ពាណិជ្ជកម្ម និងការវិនិយោគទ្វេភាគី, ការផ្សព្វផ្សាយពីសក្តានុពលរបស់កម្ពុជាក្នុងតួនាទីជាមជ្ឈមណ្ឌលផលិតកម្ម និងនវានុវត្តន៍ក្នុងតំបន់, ការពង្រីកកិច្ចសហប្រតិបត្តិការក្នុងវិស័យអប់រំ ទេសចរណ៍ វេជ្ជសាស្ត្រ ថាមពល សេវាកម្មឌីជីថល កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធពិស្តុភារ ក៏ដូចជាការបង្កើតឱកាសកសាងខ្សែច្រវាក់ផ្គត់ផ្គង់ និងភាពជាដៃគូថ្មីសម្រាប់បណ្តាក្រុមហ៊ុនអាមេរិកផងដែរ។










២. អមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោក Joseph Tate អនុប្រធានជាន់ខ្ពស់ នៃក្រុមហ៊ុន Archer Daniels Midland (ADM) ដែលជាក្រុមហ៊ុនកែច្នៃចំណីអាហារ និងជួញដូរទំនិញកសិផលអន្តរជាតិដ៏ធំមួយរបស់អាមេរិកនិងពិភពលោកដោយពិចារណាពិនិត្យលទ្ធភាពនាំយកនូវបច្ចេកវិទ្យាទំនើបនៃការកែច្នៃកសិផលឱ្យមានតម្លៃបន្ថែមខ្ពស់ (Value-added processing) និងប្រព័ន្ធគ្រប់គ្រងការផ្គត់ផ្គង់ប្រកបដោយប្រសិទ្ធភាពទៅកាន់កម្ពុជាផងដែរ ដើម្បីជំរុញដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងទាក់ទាញអ្នកវិនិយោគលំដាប់ពិភពលោកដើម្បីបង្កើតការងារ និងផ្ទេរចំណេះដឹងបច្ចេកទេសកម្រិតខ្ពស់មកកាន់កម្ពុជា។














៣. អមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោក Rob Calia អនុប្រធានក្រុមហ៊ុន និងជាប្រធានផ្នែកកិច្ចការជាមួយរដ្ឋាភិបាលរបស់ក្រុមហ៊ុន Medline ដែលជាក្រុមហ៊ុនឯកជនដ៏ធំបំផុតមួយរបស់សហរដ្ឋអាមេរិកមានឯកទេសក្នុងការផលិត ចែកចាយបរិក្ខារពេទ្យ និងផលិតផលថែទាំសុខភាពជាង ៣៣៥ពាន់មុខ និងជាអ្នកផ្តល់ដំណោះស្រាយខ្សែច្រវាក់ផ្គត់ផ្គង់ជូនស្ថាប័នថែទាំសុខភាពទូទាំងពិភពលោកផងដែរ។

ជំនួបនេះបានផ្តោតសំខាន់ក្នុងការជំរុញការវិនិយោគលើវិស័យឧស្សាហកម្មការផលិតសម្ភារៈ និងបរិក្ខារពេទ្យតាមរយៈការពិនិត្យលទ្ធភាពបង្កើតរោងចក្រផលិតនៅកម្ពុជា។









៤. អមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ លោក Andrew Gregory នាយកប្រតិបត្តិជាន់ខ្ពស់ ទទួលបន្ទុកសិទ្ធិអាជីវកម្ម និងការអភិវឌ្ឍន៍សកល នៃក្រុមហ៊ុនសាជីវកម្ម McDonald's Corporation ដោយរាជរដ្ឋាភិបាលកម្ពុជា នឹងសម្របសម្រួលជ្រោមជ្រែងគ្រប់បែបយ៉ាងសម្រាប់រាល់ការវិនិយោគរបស់ក្រុមហ៊ុន McDonald's នៅកម្ពុជា។










៥. អមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងជំនួបពិភាក្សាការងារជាមួយ លោក George A. Pickart នាយកគ្រប់គ្រងកិច្ចការរដ្ឋាភិបាល និងគោលនយោបាយសកល នៃក្រុមហ៊ុន GE Vernova ដែលឈានមុខគេផ្នែកបច្ចេកវិទ្យាថាមពលនិងការអភិវឌ្ឍបណ្តាញអគ្គិសនីប្រកបដោយនិរន្តរភាព។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានសំណូមពរឱ្យ GE Vernova ពិចារណាពង្រីកសកម្មភាពវិនិយោគបន្ថែមពីលើវត្តមានបច្ចុប្បន្នរបស់ GE នៅកម្ពុជា ដោយផ្តោតលើការផ្តល់នូវដំណោះស្រាយលើប្រព័ន្ធគ្រប់គ្រងថាមពលវៃឆ្លាតជាមួយនឹងការនាំចូលបច្ចេកវិទ្យាគ្រប់គ្រង និងផ្ទុកថាមពល (Energy Storage) ដើម្បីបង្កើនប្រសិទ្ធភាពការប្រើប្រាស់ថាមពលទូទាំងប្រទេស។






៦. ចូលរួមក្នុងកិច្ចពិភាក្សាការងារតុមូលរៀបចំដោយ ក្រុមប្រឹក្សាធុរកិច្ចអាម៉េរិក-អាស៊ាន (US-ASEAN Business Council - US ABC) ដោយបានទំនាក់ទំនងផ្ទាល់ជាមួយបណ្តាក្រុមហ៊ុនអាម៉េរិក។ កិច្ចពិភាក្សាតុមូលបានប្រព្រឹត្តទៅក្នុងបរិយាកាសបើកចំហ និងស្ថាបនា ដោយផ្តោតលើការផ្សារភ្ជាប់ឱកាសវិនិយោគជាក់ស្តែងពោលគឺជាស្ពានដ៏សំខាន់ក្នុងការកសាងទំនុកចិត្តរវាងរដ្ឋាភិបាលកម្ពុជា និងវិស័យឯកជនអាម៉េរិក ជាពិសេសការចូលរួមរបស់គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាបានផ្តល់ឱកាសឱ្យក្រុមហ៊ុនអាម៉េរិកមានឱកាសទំនាក់ទំនងផ្ទាល់ជាមួយដៃគូក្នុងស្រុកដែលមានបទពិសោធ និងលទ្ធភាពវិនិយោគរួមគ្នា (Joint Ventures) ក្នុងពេលអនាគត។ ឆ្លៀតក្នុងឱកាសនេះក្រុមប្រឹក្សាធុរកិច្ចអាម៉េរិក-អាស៊ាន ក៏បានធ្វើការបញ្ជាក់សារជាថ្មីថា ឧកញ៉ា លីម តារារិទ្ធ គឺជាទីប្រឹក្សាយុទ្ធសាស្ត្រប្រតិបត្តិ តំណាងក្រុមប្រឹក្សាធុរកិច្ចអាម៉េរិក-អាស៊ាន ប្រចាំប្រទេសកម្ពុជា។











៧. អមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រុមហ៊ុន Pfizer ដែលជាក្រុមហ៊ុនមានជំនាញឯកទេសក្នុងការសិក្សាស្រាវជ្រាវ និងផលិតឱសថឈានមុខគេបំផុតមួយរបស់ពិភពលោក។ ជំនួបនាឱកាសនេះ បានផ្តោតលើការផ្សារភ្ជាប់វិស័យឱសថ និងសុខាភិបាលកម្ពុជា ជាមួយបច្ចេកវិទ្យានិងស្តង់ដាសកលរបស់ Pfizer ពិសេសសិក្សាលទ្ធភាពនៃការពង្រីកសកម្មភាពអាជីវកម្មនៅកម្ពុជាលើការផ្គត់ផ្គង់ជាមួយលក្ខខណ្ឌពិសេសសម្រាប់ឱសថសំខាន់ៗនិងការគាំទ្រដល់កម្មវិធីសុខភាពសាធារណៈនានា។










៨. អមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រុមហ៊ុន HP (Hewlett-Packard) ដែលឈានមុខគេនៅក្នុងពិភពលោកក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន ដោយជំនួបនាឱកាសនេះបានផ្តោតលើការផ្សារភ្ជាប់វិស័យបច្ចេកវិទ្យាកម្ពុជាទៅនឹងខ្សែច្រវាក់ផ្គត់ផ្គង់សកលរបស់ HP និងការជំរុញយុគសម័យឌីជីថលនៅកម្ពុជា។











៩. អមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោក Hallie Offen ប្រធានផ្នែកកិច្ចការងារជាមួយរដ្ឋាភិបាលប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក និងពាណិជ្ជកម្មអន្តរជាតិរបស់ក្រុមហ៊ុន Motorola Inc. ដើម្បីស្វែងរកកិច្ចសហប្រតិ បត្តិការលើការអភិវឌ្ឍបច្ចេកវិទ្យាទំនាក់ទំនង សន្តិសុខសាធារណៈ និងការទាក់ទាញរោងចក្រផលិតគ្រឿងបង្គុំអេឡិចត្រូនិចមកកាន់កម្ពុជា។បន្ទាប់មកទៀត គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាបានបន្តអមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងជំនួបពិភាក្សាការងារជាមួយលោកស្រី Allison Lannarino នាយកគ្រប់គ្រងស្តីទីតំបន់អាស៊ីទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មាន (ICT)និងហេដ្ឋារចនាសម្ព័ន្ធ នៃសាជីវកម្មហិរញ្ញវត្ថុអភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាម៉េរិក (U.S.International Development Finance Corporation - DFC) ដោយផ្តោតសំខាន់លើយន្តការក្នុងការបង្កើនកិច្ចសហប្រតិបត្តិការរបស់ DFC ជាមួយប្រទេសកម្ពុជាតាមរយៈការពិនិត្យលទ្ធភាពផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗក្នុងប្រទេស និងបានបើកផ្លូវឱ្យកម្ពុជា ក្នុងការចាប់យកឱកាសទទួលបានទុនវិនិយោគដែលមានគុណភាពខ្ពស់ជួយគាំទ្រដល់ចក្ខុវិស័យនៃការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព និងទំនួលខុសត្រូវសង្គម។











១០. អមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងជំនួបសម្ដែងការគួរសម និងពិភាក្សាការងារជាមួយលោកស្រី Tisha Botman អនុប្រធានប្រតិបត្តិរបស់ក្រុមហ៊ុន Siemens Healthineers សំដៅជំរុញវិនិយោគបច្ចេកវិទ្យាវេជ្ជសាស្ត្រ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលនៅកម្ពុជា។ ជាពិសេសពិនិត្យលទ្ធភាពនៃការចូលរួមផ្គត់ផ្គង់ បំពាក់ និងថែទាំឧបករណ៍វេជ្ជសាស្ត្របច្ចេកវិទ្យាខ្ពស់នៅកម្ពុជាតែម្ដង។













ដោយឡែក ក្នុងអំឡុងពេលបំពេញបេសកកម្មនៅក្នុងទីក្រុងតូរ៉ុនតូ និងទីក្រុងម៉ុងត្រេអាល់ ប្រទេសកាណាដា គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា បានចូលរួមក្នុងកម្មវិធីសំខាន់ៗជាបន្តបន្ទាប់រួមមាន៖

១. អមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ លោកជំទាវ Caroline Mulroney សមាជិកសភានៃរដ្ឋបាលខេត្តអុនតារីយ៉ូ និងជារដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនិយាយភាសាបារាំង និងជាប្រធានក្រុមប្រឹក្សាភិបាលរតនាគារខេត្តអុនតារីយ៉ូ ប្រទេសកាណាដា។ លោកជំទាវបានបង្ហាញនូវការកោតសរសើរចំពោះវឌ្ឍនភាពដ៏គួរឱ្យកត់សម្គាល់របស់កម្ពុជា និងបានគាំទ្រលើការគិតគូររៀបចំវេទិកាវិនិយោគ និងពាណិជ្ជកម្មកំឡុងពេលកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ នៅប្រទេសកម្ពុជា នាឆ្នាំ២០២៦ ខាងមុខ។










២. អមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល បំពេញទស្សនកិច្ចនៅការិយាល័យកណ្តាលនៃក្រុមហ៊ុនសាជីវកម្ម Manulife Financial Corporation និងបន្តដោយកិច្ចពិភាក្សាការងារតុមូលដោយមានការអញ្ជើញចូលរួមពីសំណាក់ លោកជំទាវ Sara Wilshaw ជំនួយ ការជាន់ខ្ពស់អមអនុរដ្ឋមន្ត្រីពាណិជ្ជកម្មអន្តរជាតិ និងជាឧត្តមស្នងការពាណិជ្ជកម្ម នៃក្រសួងកិច្ចការសកលរបស់កាណាដា (Global Affair Canada – GAC) និងថ្នាក់ដឹកនាំពីស្ថាប័នពាក់ព័ន្ធរួមមាន៖ ធនាគារជាតិនៃកាណាដា (National Bank of Cananda – NBC), ក្រុមហ៊ុនសាជីវ កម្ម Manulife Financial Corporation, និង ក្រុមប្រឹក្សាធុរកិច្ចកាណាដា-អាស៊ាន (Canada-ASEAN Business Council – CABC) ដោយមានគោលបំណងសំខាន់ៗរួមមានជាអាទិ៍ ៖ (១)ការអភិវឌ្ឍទំនាក់ទំនង និងការលើកកម្ពស់កិច្ចសន្ទនាស្តីពីយុទ្ធសាស្ត្រជាក់ស្តែង ក្នុងការពង្រីកកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទ្វេភាគីរវាងកាណាដា និងកម្ពុជា, (២)ការទាក់ទាញវិនិយោគ តាមរយៈការផ្សព្វផ្សាយពីសក្តានុពលវិនិយោគនៅកម្ពុជា និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលកម្ពុជាក្នុងការកែលម្អបរិយាកាសធុរកិច្ច, និង (៣) ស្វែងរកឱកាសដើម្បីចែករំលែកជំនាញបច្ចេកទេសរបស់កាណាដាទៅកម្ពុជាសំដៅអភិវឌ្ឍមូលធនមនុស្សឱ្យសមស្របទៅនឹងតម្រូវការរបស់ធុរកិច្ចជាពិសេសក្នុងវិស័យអាទិភាព។








៣. អមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម Victor Fed រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍សេដ្ឋកិច្ច ការបង្កើតការងារ និងពាណិជ្ជកម្ម នៃខេត្តអុនតារីយ៉ូ ដោយបានផ្តោតលើការពង្រឹង និងពង្រីកទំនាក់ទំនងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការវិនិយោគរវាងកម្ពុជា និងខេត្តអុនតារីយ៉ូ ដែលជាខេត្តសេដ្ឋកិច្ចដ៏ធំ និងមានបច្ចេកវិទ្យាជឿនលឿនរបស់កាណាដា។









៤. អមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោក Khawar Nasim នាយកប្រតិបត្តិ នៃស្ថាប័ន Invest Ontario និង លោក Bernie Derible ជំនួយការរបស់អនុរដ្ឋមន្ត្រីផ្នែកកសិកម្ម អ្នកប្រឹក្សាយោបល់ពិសេសនិងជាភ្នាក់ងារទូទៅរបស់ខេត្តអុនតារីយ៉ូ សម្រាប់អាស៊ាន ក្នុងគោលបំណងដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ការវិនិយោគ និងកសិកម្ម រវាងកម្ពុជា និងខេត្តអុនតារីយ៉ូ ដែលជាខេត្តមានសក្តានុពលសេដ្ឋកិច្ចធំជាងគេនៅកាណាដា តាមរយៈការជំរុញវិនិយោគិនកាណាដាមកស្វែងយល់បន្ថែមអំពីសក្តានុពលវិនិយោគនៅកម្ពុជាក្នុងវិស័យកសិ-ឧស្សាហកម្ម, ឧស្សាហកម្មកែច្នៃចំណីអាហារ,ឧស្សាហកម្មបច្ចេកវិទ្យា, ឧស្សាហកម្មយានយន្ត និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាដើម។







៥. បំពេញទស្សនកិច្ចនៅសហគ្រាសផលិតទឹកផ្លែឈើរបស់សម្ព័ន្ធ Lee Li Holdings Group ស្ថិតនៅក្នុងទីក្រុងតូរ៉ុនតូ ខេត្តអុនតារីយ៉ូ ប្រទេសកាណាដា ដើម្បីសិក្សាស្វែងយល់ឱ្យបានស៊ីជម្រៅអំពីហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងការងារ និងខ្សែច្រវាក់ផលិតកម្មទ្រង់ទ្រាយធំរបស់សហគ្រាសដែលកំពុងដំណើរការដោយប្រើប្រាស់បច្ចេកវិទ្យាទំនើបស្វ័យប្រវត្តិកម្មខ្ពស់និងស្តង់ដារគុណភាពអន្តរជាតិក្នុងការកែច្នៃផលិតផលភេសជ្ជៈដែលអាចជាគំរូសម្រាប់លើកកម្ពស់វិស័យកែច្នៃម្ហូបអាហារ និងកសិ-ឧស្សាហកម្មនៅកម្ពុជា។










៦. ចូលរួមសិក្ខាសាលាធុរកិច្ចកាណាដា រៀបចំនៅទីស្នាក់ការកណ្តាល ធនាគារជាតិនៃកាណាដា (National Bank of Canada – NBC) ក្រោមអធិបតីភាព ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងពង្រីកទំនាក់ទំនងសេដ្ឋកិច្ច-ពាណិជ្ជកម្មក៏ដូចជាការបង្កើនលំហូរវិនិយោគពីប្រទេសកាណាដាមកកាន់ប្រទេសកម្ពុជាដោយមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំនិងតំណាងក្រុមហ៊ុន/សហគ្រាសកាណាដាយ៉ាងច្រើនកុះករ។សិក្ខាសាលានេះបានប្រព្រឹត្តិទៅដោយរលូនប្រកបដោយលទ្ធផលជាផ្លែផ្កានិងបានដើរតួជាវេទិកាមួយសម្រាប់ក្រុមហ៊ុនកាណាដាដែលបានស្វែងយល់ពីកម្ពុជារួចហើយអាចធ្វើការសម្រេចចិត្តវិនិយោគជាក់ស្តែង និងពង្រីកប្រតិបត្តិការរបស់ខ្លួនក្នុងទីផ្សារអាស៊ីអាគ្នេយ៍តាមរយៈការប្រើប្រាស់កម្ពុជាជាមូលដ្ឋានផលិតកម្ម និងនាំចេញ។












៧. ចូលរួមជំនួបពិភាក្សាការងារតុមូលជាមួយបណ្តាក្រុមហ៊ុន សហគ្រាស និងស្ថាប័នធុរកិច្ចរបស់កាណាដា ដែលមានចំណាប់អារម្មណ៍លើទីផ្សារកម្ពុជាដោយស្ថាប័នធុរកិច្ចចំនួន ១៤មកពីវិស័យច្បាប់, ហិរញ្ញវត្ថុ និងធនាគារ,សារព័ត៌មាន និងសិល្បៈកម្សាន្ត, អប់រំ, សំណង់ , ចំណីអាហារ និងឧស្សាហកម្មផ្នែកកសិ-ចំណីអាហារ, ទំនាក់ទំនងអន្តរជាតិ និងផ្នែកផ្តល់សេវាវិជ្ជាជីវៈដែលរួមមានដូចជា៖

- ធនាគារ Royal Bank of Canada (RBC) ដែលផ្តល់សេវាហិរញ្ញវត្ថុពហុជាតិសាសន៍របស់កាណាដា និងជាធនាគារដ៏ធំជាងគេបំផុតនៅក្នុងប្រទេសដោយផ្អែកលើទំហំមូលធនទីផ្សារ (market capitalization)
- ក្រុមហ៊ុនច្បាប់អន្តរជាតិ Fasken
- ក្រុមហ៊ុន Caisse de dépôt et placement du Québec (CDPQ) ដែលគ្រប់គ្រងមូលនិធិស្ថាប័នដ៏ធំបំផុតមួយនៅក្នុងប្រទេសកាណា ដា និងអាម៉េរិកខាងជើង

- ក្រុមហ៊ុន Cirque du Soleil ដែលវិនិយោគលើការកម្សាន្តនិងធ្វើបដិវត្តន៍លើទម្រង់សិល្បៈសៀកប៉េបទំនើបដោយផ្តោតលើភាពអស្ចារ្យនៃសិល្បៈ កាយសម្ព័ន្ធ ការរចនាឆាក និងសំឡេងតន្ត្រីជាជាងការប្រើប្រាស់សត្វ
- Centre Hospitalier de l’Université de Montréal (CHUM) ដែលជាមន្ទីរពេទ្យសាកលវិទ្យាល័យដ៏ធំ និងទំនើបបំផុតមួយនៅអាមេរិកខាងជើងដែលមានទីតាំងនៅទីក្រុងម៉ុងត្រេអាល់
- ក្រុមហ៊ុន Brivia Group ដែលវិនិយោគ និងអភិវឌ្ឍន៍អចលនទ្រព្យដ៏លេចធ្លោមួយនៅកាណាដា
- ក្រុមហ៊ុន Pomerleau វិនិយោគលើវិស័យសំណង់ដ៏ធំជាងគេមួយនៅកាណាដា ដែលមានឯកទេសលើគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ សំណង់អគារ និងវិស្វកម្មស៊ីវិលខ្នាតធំ
- ក្រុមហ៊ុន MTY Food Group Inc. ដែលផ្តល់សិទ្ធិអាជីវកម្ម (Franchisor) ដ៏ធំបំផុតមួយនៅក្នុងឧស្សាហកម្មម្ហូបអាហាររបស់ទ្វីបអាមេរិកខាងជើង
- Power Corporation of Canada (POW) ដែលជាក្រុមហ៊ុនគ្រប់គ្រង និងកាន់កាប់លើវិស័យសេវាហិរញ្ញវត្ថុ
- ធនាគារ Scotiabank ជាស្ថាប័នផ្តល់សេវាហិរញ្ញវត្ថុអន្តរជាតិដ៏លេចធ្លោមួយរបស់កាណាដា
- ក្រុមហ៊ុន Olymel L.P. ដែលវិនិយោគលើឧស្សាហកម្មកសិ-ចំណីអាហារដ៏ធំជាងគេមួយនៅកាណាដា និងជាក្រុមហ៊ុនឈានមុខគេក្នុងការផលិត កែច្នៃ និងចែកចាយសាច់ជ្រូក និងសាច់បសុបក្សី
- ស្ថាប័ន Conseil des relations internationales de Montréal (CORIM) ជាក្រុមប្រឹក្សាទំនាក់ទំនង
- អន្តរជាតិនៃម៉ុងត្រេអាល់ដែលជាស្ថាប័នសំខាន់មួយនៅដែលដើរតួនាទីជាវេទិកាក្នុងការផ្សព្វផ្សាយនិងពិភាក្សាអំពីកិច្ចការអន្តរជាតិ
- ក្រុមហ៊ុន Investissement Québec ជាសាជីវកម្មហិរញ្ញវត្ថុ និងជាទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចផ្លូវការរបស់
- រដ្ឋបាលខេត្តកេប៊ិច ប្រទេសកាណាដា
- ក្រុមហ៊ុន Deloitte Canada ដែលផ្តល់សេវាវិជ្ជាជីវៈធំជាងគេនៅកាណាដា និងជាផ្នែកនៃបណ្តាញសកល Deloitte Touche Tohmatsu Limited ដែលជាបណ្តាញផ្តល់សេវាដ៏ធំមួយក្នុងចំណោមបួនធំៗលើពិភពលោក









៨. ចូលរួមកម្មវិធីទទួលទានអាហារថ្ងៃត្រង់ធុរកិច្ចដើម្បីបង្កើនបណ្តាញទំនាក់ទំនងរវាងសហគមន៍ធុរកិច្ចកម្ពុជា និងកាណាដាដោយមានការចូលរួមពីសំណាក់ភ្ញៀវកិត្តិយសប្រមាណជាង ៥០រូប ដែលភាគច្រើនគឺជាឥស្សរជនរបស់រដ្ឋាភិបាលសហព័ន្ធ, រដ្ឋបាលខេត្តកេប៊ិច, រដ្ឋបាលក្រុងម៉ុងត្រេអាល់ និងជាថ្នាក់ដឹកនាំធុរកិច្ចដ៏លេចធ្លោនៅក្នុងទីក្រុងម៉ុងត្រេអាល់ និងខេត្តកេប៊ិចផ្ទាល់។ ព្រឹត្តិការណ៍នេះមានសារៈសំខាន់ខ្លាំងលើផ្នែកសេដ្ឋកិច្ច និងនយោបាយ ដោយផ្តល់ឱកាសពិសេសសម្រាប់គណៈប្រតិភូកម្ពុជាបានជួបផ្ទាល់ជាមួយអ្នកតាក់តែងគោលនយោបាយ និងអ្នកសម្រេចចិត្តនៅកម្រិតសហព័ន្ធ ខេត្ត និងក្រុង ដែលតំណាងឱ្យក្រុងម៉ុងត្រេអាល់ដែលជាមជ្ឈមណ្ឌលសេដ្ឋកិច្ច នៃកាណាដា។



















៩. អមដំណើរឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងកិច្ចពិភាក្សាស្វែងយល់ពីការគ្រប់គ្រងឧទ្យានបច្ចេកវិទ្យា “Technoparc Montréal” និងការអភិវឌ្ឍជាតំបន់សេដ្ឋកិច្ចចីរភាព សំដៅទាក់ទាញចង្កោមឧស្សាហកម្មដ៏ជោគជ័យរបស់កាណាដា ជាពិសេសនៅក្នុងវិស័យអវកាសយាន (Aerospace) និងបច្ចេកវិទ្យាទំនើប។

















១០. អមដំណើរឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល បំពេញទស្សនកិច្ចនៅក្រុមហ៊ុន YKK Canada Inc. ដែលផលិតគ្រឿងបង្គុំសម្លៀកបំពាក់ (រូត) ដ៏ល្បីល្បាញនៅលើពិភពលោក ព្រមទាំងបានពិភាក្សាការងារជាមួយ ប្រធានក្រុមហ៊ុនគឺ លោក Hugues Charbonneau ផងដែរ ក្នុងគោលបំណងដើម្បសិក្សាស្វែងយល់អំពីហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងការងារនិងខ្សែច្រវាក់ផលិតកម្មទ្រង់ទ្រាយធំរបស់ក្រុមហ៊ុន សំដៅទាក់ទាញក្រុមហ៊ុនឱ្យពិនិត្យលទ្ធភាព និងសិក្សាឱកាសក្នុងការពង្រីកមូលដ្ឋានផលិតកម្មរបស់ខ្លួននៅក្នុងប្រទេសកម្ពុជាដើម្បីពង្រឹងខ្សែច្រវាក់ផ្គត់ផ្គង់សម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរដែលជាវិស័យដ៏សំខាន់មួយរបស់កម្ពុជា។













ជាការកត់សម្គាល់ តាមរយៈបេសកកម្មនេះគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាទទួលបាននូវលទ្ធផលជាផ្លែផ្កា ដូចជា ១) អ្នកឧកញ៉ា ស្ងួរ វីរៈ សមាជិក នៃសមាគមឧកញ៉ាកម្ពុជា និងជាអគ្គនាយកក្រុមហ៊ុន វីរៈ ប៊ុនថាំ អេចប្រេស ទទួលបានការព្រមព្រៀង និងគ្រោងនាំចេញអង្ករកម្ពុជា ដើម្បីនាំយកលក់សាកល្បងនៅលើទីផ្សារសហរដ្ឋអាម៉េរិក និងកាណាដា  ខណៈដែលធុរជននៃប្រទេសទាំងពីរក៏បានបង្ហាញការគាំទ្រក្នុងការទទួលទិញយករាល់ផលិតផលខ្មែរទាំងអស់ដែលអាចនាំចេញបានដូចជា ស្វាយចន្ទី ក៏ដូចជាផលិតផលផ្សេងៗពាក់ព័ន្ធនឹងចំណីអាហារផងដែរ, ២) បានចែករំលែកអំពីសាវតារ បេសកកម្ម និងតួនាទីស្នូលរបស់សមាគម ដែលជាបណ្តុំធុរជនដ៏មានសក្តានុពល ព្រមទាំងកសាងបណ្តាញ  ការបង្កើតយន្តការទំនាក់ទំនង  និងការផ្តួចផ្តើមធុរកិច្ចជាមួយស្ថាប័ន/សភាពាណិជ្ជកម្ម/វិស័យឯកជន  ទាំងនៅសហរដ្ឋអាម៉េរិក  និងកាណាដា សម្រាប់កិច្ចសហប្រតិបត្តិការធុរកិច្ចនាអនាគត។

# អ្នកឧកញ៉ា ផៃ ហុកឈួន ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធនៅវិមានឯករាជ្យ និងថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ



នារសៀលថ្ងៃសៅរ៍ ៣រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៥ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានចាត់តាំង អ្នកឧកញ៉ា ផៃ ហុកឈួន អនុប្រធាន និងជាប្រធានគណៈកម្មការរដ្ឋបាល ហិរញ្ញវត្ថុ និងធនាគារ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា អញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធនៅវិមានឯករាជ្យ រួចបន្តថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណាសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "**ព្រះបរមរតនកោដ្ឋ**" នៅមណ្ឌបព្រះបរមរូប ខាងកើតវិមានឯករាជ្យក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី៧២ ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា។

នេះជាការរំលឹកនឹកដល់ព្រះរាជគុណូបការៈ និងព្រះមហាវីរភាពដ៏ធំធេងរបស់ **ព្រះករុណាព្រះបរមរតនកោដ្ឋ** ដែលបានបំពេញព្រះរាជបូជនីយកិច្ច និងបូជាអស់កម្លាំងព្រះកាយពលព្រះបញ្ញាញាណក្នុងការដណ្តើមឯករាជ្យពីប្រទេសបារាំងជូនជាតិមាតុភូមិជាទីស្រលាញ់របស់ព្រះអង្គ ក៏ដូចជាពលិកម្មប្រកបដោយវីរភាពដ៏អង់អាចរបស់យុទ្ធជនក៏ដូចជាប្រជាពលរដ្ឋខ្មែរប្រុសស្រី ប្រកបដោយសាមគ្គីភាពក្នុងការដណ្តើមបានមកវិញនូវសិទ្ធិសេរីភាព និងភាពជាម្ចាស់ទឹកដីរបស់ប្រជាជាតិកម្ពុជានេះផងដែរ។















# ថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ចូលរួមខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា











នៅព្រឹកថ្ងៃអាទិត្យ ៤រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២៥ ថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ជាច្រើនរូបបានអញ្ជើញចូលរួមខួបអនុស្សាវរីយ៍៧២ឆ្នាំ នៃទិវាបុណ្យឯករាជ្យជាតិ៩ វិច្ឆិកា នៅវិមានឯករាជ្យ រាជធានីភ្នំពេញក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត ព្រះករុណាព្រះបាទសម្តេច **ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សម្តេចយាងជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត ក្នុងខួបអនុស្សាវរីយ៍៧២ឆ្នាំ នៃទិវាបុណ្យឯករាជ្យជាតិ៩ វិច្ឆិកា នៅវិមានឯករាជ្យ រាជធានីភ្នំពេញ។

ព្រះរាជពិធីផ្លូវការនៃទិវាបុណ្យឯករាជ្យជាតិលើកទី៧២ នេះក៏មានការយាង និងអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ ស្ថាប័នកំពូលៗរបស់កម្ពុជា មានសមាជិកព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ភ្ញៀវជាតិ អន្តរជាតិ មន្ត្រីទូតនានា មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ យុវជន យុវតី សិស្សានុសិស្ស និងមហាជនយ៉ាងច្រើនកុះករ។

ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា បានរំលឹកឱ្យឃើញពីព្រះរាជបេសកកម្មដើម្បីជាតិមាតុភូមិ និងប្រជារាស្ត្រខ្មែរ របស់ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ** ព្រះបិតាឯករាជ្យជាតិ ព្រះបរមរតនកោដ្ឋ ដែលព្រះអង្គបានលះបង់ព្រះកាយពល និងព្រះបញ្ញាញាណយ៉ាងក្លៀវក្លាបំផុត ធ្វើការតស៊ូ ក្នុងក្របខណ្ឌនៃព្រះរាជបូជណីយកិច្ច ដើម្បីទាមទារឯករាជ្យដ៏ពិតប្រាកដនៅកម្ពុជា៕





















នៅរសៀលថ្ងៃអង្គារ ៦រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៥ អ្នកឧកញ៉ា ទី គឹមស្រ៊ាន សមាជិកក្រុមប្រឹក្សាភិបាល នៃសមាគមឧកញ៉ាកម្ពុជា រួមជាមួយអ្នកឧកញ៉ា ឧកញ៉ា ជាច្រើនរូបដែលជាសមាជិកសមាគមឧកញ៉ាកម្ពុជា បានចូលរួមក្នុងព្រះរាជពិធីពន្លត់ភ្លើងជ័យ នៃខួបលើកទី៧២ឆ្នាំ ទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត ព្រះករុណា ព្រះបាទសម្តេច **ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

ព្រះរាជពិធីនេះក៏មានការអញ្ជើញដង្ហែព្រះរាជដំណើរដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី ព្រមទាំងឥស្សរជន ជាសមាជិកឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល ក៏ដូចជាប្រជាពលរដ្ឋខ្មែរ និងសិស្សានុសិស្សជាច្រើនកុះករ៕














# អ្នកឧកញ៉ា គួន ធីតា អនុប្រធានសមាគម តំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ដឹកនាំ សមាជិកសមាគម ចូលរួម «ជំនួបផ្គូផ្គងធុរកិច្ចឥណ្ឌា-កម្ពុជា»

នាល្ងាចថ្ងៃអង្គារ ទី១១ ខែវិច្ឆិកា ឆ្នាំ២០២៥ អ្នកឧកញ៉ា គួន ធីតា អនុប្រធានសមាគម និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំសមាជិកចូលរួម «ជំនួបផ្គូផ្គងធុរកិច្ចឥណ្ឌា-កម្ពុជា» ក្នុងវិស័យសុខាភិបាល ដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារ សាងគ្រីឡា ភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តម Vanlalvawna Bawitlung ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌា ប្រចាំព្រះរាជាណាចក្រកម្ពុជា ដោយមានការចូលរួមពីតំណាងក្រសួង-ស្ថាប័នរដ្ឋ សភាពាណិជ្ជកម្ម សមាគមវិស័យឯកជន និងភាគីពាក់ព័ន្ធជា ច្រើនរូបមកពីប្រទេសទាំងពីរ។

គោលបំណងនៃជំនួបផ្គូផ្គងធុរកិច្ចនេះគឺដើម្បីជាវេទិកាសម្រាប់ធុរជនកម្ពុជា និងឥណ្ឌាជួបជុំគ្នាកសាងទំនាក់ទំនងធុរកិច្ច និងស្វែងរកឱកាសចាប់ដៃគូវិនិយោគទៅវិញទៅមកក្នុងវិស័យសុខាភិបាល ដោយផ្តោតជាពិសេសលើផ្នែកវេជ្ជសាស្ត្រ និងឱសថ ក៏ដូចជាលើកកម្ពស់ការយល់ដឹងអំពីនីតិវិធីផ្លូវច្បាប់នានាពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មក្នុងវិស័យទាំងនេះផងដែរ។


















# អ្នកឧកញ៉ា សៀ ឬទ្ធី អនុប្រធានសមាគម និងជាប្រធានគណៈកម្មការ ទំនាក់ទំនងសាធារណៈ អន្តរជាតិ និងទេសចរណ៍ ដឹកនាំកិច្ចប្រជុំពិភាក្សាការងារផ្ទៃក្នុង នៃអនុគណៈកម្មការទំនាក់ទំនង និងធុរកិច្ច (អទធ) លើកទី១ ឆ្នាំ២០២៥

នាព្រឹកថ្ងៃអង្គារ ទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៥ អ្នកឧកញ៉ា សៀ ឬទ្ធី អនុប្រធានសមាគមឧកញ៉ាកម្ពុជា និងជាប្រធានគណៈកម្មការទំនាក់ទំនងសាធារណៈ អន្តរជាតិ និងទេសចរណ៍ បានដឹកនាំ "កិច្ចប្រជុំអនុគណៈកម្មការទំនាក់ទំនង និងធុរកិច្ច (អទធ) លើកទី១ ឆ្នាំ២០២៥ " ដោយមានការចូលរួមពីអ្នកឧកញ៉ា គួន ធីតា អនុប្រធានសមាគម និងជាប្រធានអនុគណៈកម្មការ, អ្នកឧកញ៉ាហ៊ុន ឡាក់ អគ្គលេខាធិការ និងជាអនុប្រធានអនុគណៈកម្មការ, ឧកញ៉ា សូ សុខប៊ុនលីម អនុប្រធានអនុគណៈកម្មការ, ឧកញ៉ា ជា ដាណា និងឧកញ៉ា ស៊ន សុទ្ធី ដែលជាសមាជិកអនុគណៈកម្មការ។ កិច្ចប្រជុំនេះបានប្រព្រឹត្តទៅនៅទីស្នាក់ការសមាគមឧកញ៉ាកម្ពុជាដើម្បីពិភាក្សា និងផ្តល់ធាតុចូលលើរបៀបវារៈសំខាន់ៗដូចខាងក្រោម៖

១. ការរៀបចំ "សន្និបាតលើកទី៣" របស់សមាគមឧកញ៉ាកម្ពុជា និង "ការរៀបចំវេទិកាធុរកិច្ចរវាងសមាគមឧកញ៉ាកម្ពុជា, សភាពាណិជ្ជកម្មចិននៅហុងកុង និងធុរជនចិន"

២. ការរៀបចំផែនការសកម្មភាពទំនាក់ទំនង និងធុរកិច្ចសម្រាប់ឆ្នាំ២០២៦

៣. ការរៀបចំពិធីជួបជុំ និងពិសាភោជនាហារសាមគ្គីនៃគ្រួសារសមាគមឧកញ៉ាកម្ពុជា

កិច្ចប្រជុំនេះបានប្រព្រឹត្តទៅដោយរលូនដោយមានការផ្លាស់ប្តូរមតិយោបល់យ៉ាងផុសផុលពីសមាជិក និងសម្រេចបានលទ្ធផលវិជ្ជមានសម្រាប់ជាផែនការសកម្មភាពអនុវត្តក្នុងឆ្នាំ២០២៦ ខាងមុខនេះ។









# អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ នៃសមាគមឧកញ៉ាកម្ពុជា ចូលរួម «វេទិកាបង្ហាញសក្តានុពលអាជីវកម្ម និងឧស្សាហកម្មគាំទ្រនៅកម្ពុជា លើកទី១» ក្រោមអធិបតីភាពឯកឧត្តម ហែម វណ្ណឌី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ និងនវានុវត្តន៍

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៥នេះ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ នៃសមាគមឧកញ៉ាកម្ពុជាបានចូលរួម «វេទិកាបង្ហាញសក្តានុពលអាជីវកម្ម និងឧស្សាហកម្មគាំទ្រនៅកម្ពុជា លើកទី១» ក្រោមអធិបតីភាពឯកឧត្តម ហែម វណ្ណឌី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ដោយមានការចូលរួមពីក្រសួង/ស្ថាប័នរដ្ឋ សមាគម និងអង្គការជាតិ/អន្តរជាតិដែលពាក់ព័ន្ធ អ្នកដឹកនាំឧស្សាហកម្ម ក្រុមហ៊ុនពហុជាតិ សហគ្រាសផលិតក្នុងស្រុកដែលមានសក្តានុពលក៏ដូចជាដៃគូអភិវឌ្ឍន៍ និងអ្នករៀបចំគោលនយោបាយ ប្រមាណ ២៥០នាក់។

វេទិកានេះត្រូវបានរៀបចំឡើងរយៈពេលពេញមួយថ្ងៃ ដោយផ្តោតលើសារៈសំខាន់នៃការកសាងខ្សែច្រវាក់ផលិតកម្មក្នុងស្រុកឱ្យកាន់តែរឹងមាំ និងលើកកម្ពស់សមត្ថភាពសហគ្រាសធុនតូច និងមធ្យមក្នុងស្រុកឱ្យក្លាយជាកម្លាំងជំរុញបរិវត្តកម្មឧស្សាហកម្មដោយបានពិភាក្សាលើសសរស្តម្ភចំនួនបីគឺ៖

(១).ការកំណត់យថាប្រភេទអាជីវកម្មកំពុងលូតលាស់ និងមានសក្តានុពលខ្ពស់

(២).ការបង្កើតខ្សែច្រវាក់តភ្ជាប់រវាងការផ្គត់ផ្គង់ និងតម្រូវការទាំងក្នុងស្រុក បង្គ្រប់ការនាំចូល ជំនួសការនាំចូល និងបង្កើនការនាំចេញ

(៣).ការពង្រឹងបរិយាកាសអំណោយផលសម្រាប់សក្តានុពលអាជីវកម្ម និងឧស្សាហកម្មគាំទ្រនៅកម្ពុជា។








សូមបញ្ជាក់ថា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានកំណត់ផលិតផលអាទិភាពក្នុងអនុវិស័យចំនួន៧ ដែលផ្តល់ឱកាសទីផ្សារភ្លាមៗ និងភាពពាក់ព័ន្ធជាយុទ្ធសាស្ត្រសម្រាប់ការពង្រឹងខ្សែច្រវាក់តម្លៃក្នុងស្រុក និងឧស្សាហកម្មប្រតិគមន៍របស់កម្ពុជាដែលរួមមានអនុវិស័យ ១. វាយនភណ្ឌ, ២. អាហារ និងភេសជ្ជៈ, ៣. កៅស៊ូ និងផ្លាស្ទិក, ៤. កម្មន្តសាលគីមី និងផលិតផលប្រើប្រាស់ប្រចាំថ្ងៃ, ៥. កម្មន្តសាលគ្រឿងបង្គុំយានយន្ត និងអេឡិចត្រូនិច, ៦. ការវេចខ្ចប់ និងផ្លាកសញ្ញា, និង ៧. គ្រឿងសង្ហារឹម ក្នុងគោលបំណងកៀរគរការវិនិយោគក្នុងស្រុកនៅក្នុងអនុវិស័យសក្តានុពលទាំង៧, ពង្រឹងការតភ្ជាប់ខ្សែច្រវាក់ផ្គត់ផ្គង់រវាងសហគ្រាសធុនតូចនិងមធ្យមជាមួយនឹងរោងចក្រធុនធំ និងឧស្សាហកម្ម, លើកកម្ពស់សមត្ថភាព និងគុណភាពផលិតផលតាមរយៈការចាប់យកបច្ចេកវិទ្យា គ្រឿងម៉ាស៊ីន ឌីជីថលភាវូបនីយកម្ម, ជំរុញការអនុវត្តតាមស្តង់ដារជាតិ និងអន្តរជាតិដូចជា ISO, GMP និង GHP, ព្រមទាំងលើកកម្ពស់ការប្រើប្រាស់ផលិតផលក្នុងស្រុក និងពង្រីកការនាំចេញរបស់សហគ្រាសកម្ពុជា។











# ថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ចូលរួមកម្មវិធី Bridge Reverse & Chateau Angelus Night ដែលត្រូវបានរៀបចំដោយ ក្រុមហ៊ុន WorldBridge Group




កាលពីល្ងាចថ្ងៃសុក្រ ទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥ អ្នកឧកញ៉ា ឧកញ៉ា ជាថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា បានចូលរួមក្នុងកម្មវិធី BRIDGE RESERVE & Château Angelus Night ដែលត្រូវបានរៀបចំឡើងដោយក្រុមហ៊ុន WorldBridge Group ដែលមានអ្នកឧកញ៉ា សៀ ឫទ្ធី ជាប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន។

កម្មវិធីនេះ មិនត្រឹមតែជាព្រឹត្តិការណ៍លើកទីមួយសម្រាប់ធនាគារប្រ៊ីដនិងក្រុមហ៊ុន Auskhmer ដែលជាបុត្រសម្ព័ន្ធរបស់ WorldBridge Group ក្នុងការផ្តល់ជូននូវបណ្ណ BRDIGE VISA RESERVE និងការភ្លក្សរសជាតិនៃ Château Angelus ដែលមានគុណភាពខ្ពស់ពីទីក្រុង Bordeaux ប្រទេសបារាំងជូនភ្ញៀវកិត្តិយសដែលបានអញ្ជើញចូលរួមប៉ុណ្ណោះទេ ប៉ុន្តែនេះគឺជាជំហានដ៏សំខាន់មួយសម្រាប់ការកែលម្អប្រព័ន្ធសេវាហិរញ្ញវត្ថុឌីជីថលនៅកម្ពុជាដែលបានបង្ហាញពីការប្តេជ្ញារបស់ធនាគារក្នុងការផ្តល់នូវសេវាកម្មឯកជនភាពមួយដែលមានប្រសិទ្ធភាព សុវត្ថិភាព និងងាយស្រួលសមស្របទៅនឹងការប្រកួតប្រជែងក្នុងសម័យឌីជីថលក៏ដូចជាចំណុចចាប់ផ្តើមថ្មីមួយសម្រាប់ទិសដៅនាវានុវត្តន៍ និងអភិវឌ្ឍន៍ឥណទានឌីជីថលនិងសេវាហិរញ្ញវត្ថុទំនើបនៅកម្ពុជាផងដែរ។











BRIDGE
ANGELUS
BRIDGE

BRIDGE
ANGELUS
BRIDGE




ANGELUS

BRIDGE
ANGELUS

## អ្នកឧកញ៉ា គួន ធីតា អនុប្រធានសមាគម ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីសម្ពោធ «មជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ច និងសហគ្រិនភាពស្ត្រី (ម.ស.ស.ស.) ក្រោមអធិបតីភាពលោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត








នាថ្ងៃពុធ ទី៣ ខែធ្នូ ឆ្នាំ២០២៥ អ្នកឧកញ៉ា គួន ធីតា អនុប្រធានសមាគមឧកញ៉ាកម្ពុជា បានចូលរួមក្នុងពិធីសម្ពោធ " មជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ច និងសហគ្រិនភាពស្ត្រី (ម.ស.ស.ស.)" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី** ដែលមានទីតាំងស្ថិតនៅសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

ក្នុងឱកាសនេះដែរ **លោកជំទាវបណ្ឌិត** បានមានប្រសាសន៍សង្កត់ធ្ងន់ថា៖ " ស្ត្រីគឺជាកម្លាំងចលករដ៏សំខាន់ក្នុងការរួមចំណែកលើកកម្ពស់កិច្ចអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិឱ្យកាន់តែមានភាពធន់ និងកាន់តែប្រសើរឡើង"។ **លោកជំទាវ** បានបន្ថែមថា ការលេចចេញជារូបរាងនៃមជ្ឈមណ្ឌលថ្មីនេះ គឺជាសក្ខីភាពបញ្ជាក់ពីការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាចំពោះការអភិវឌ្ឍសមត្ថភាពស្ត្រី។

សូមបញ្ជាក់ថា មជ្ឈមណ្ឌលនេះបានបង្កើតឡើងក្នុងគោលបំណងអភិវឌ្ឍសហគ្រិនភាព និងបង្កើនការចូលរួមរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច ដោយផ្តោតលើមុខងារសំខាន់ៗចំនួន ៤ រួមមាន៖ ១. ការអភិវឌ្ឍសមត្ថភាពផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី, ២. កម្មវិធីគាំទ្រការចាប់ផ្តើម និងអភិវឌ្ឍសហគ្រិនភាពស្ត្រី, ៣. ការលើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍, ៤. ការពង្រីកបណ្តាញ និងតភ្ជាប់ទីផ្សារផលិតផល/សេវាកម្មទាំងក្នុងស្រុក តំបន់ និងសកលលោក។

សម្រាប់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ ក្រោមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ បានបន្តកំណត់យកការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីជាអាទិភាពដោយចាត់ទុកថា "ស្ត្រី គឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ"៕













# ឧកញ៉ា កង លាប សមាជិកក្រុមប្រឹក្សាភិបាល ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីបើក «ពិព័រណ៍ពាណិជ្ជកម្មកម្ពុជាលើកទី១៨ ឆ្នាំ២០២៥» ក្រោមអធិបតីភាព ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

នាថ្ងៃព្រហស្បតិ៍ ទី៤ ខែធ្នូ ឆ្នាំ២០២៥នេះ ឧកញ៉ា កង លាប សមាជិកក្រុមប្រឹក្សាភិបាល នៃសមាគមឧកញ៉ាកម្ពុជា រួមជាមួយឧកញ៉ា ម៉ៅ បញ្ញពណ៌, អ្នកឧកញ៉ា សំ សុខនឿន និងឧកញ៉ាវេជ្ជបណ្ឌិត ជា សុខឃាង បានចូលរួមក្នុងពិធីបើក "ពិព័រណ៍ពាណិជ្ជកម្មកម្ពុជា (CTExpo) លើកទី១៨ ឆ្នាំ២០២៥" ក្រោមអធិបតីភាពឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រព្រឹត្តទៅនៅសាលសន្និបាតភីអេច ប្រ្គនេហល បុរីប៉េងហួត បឹងស្នោ រាជធានីភ្នំពេញ ដែលជាព្រឹត្តិការណ៍ពិព័រណ៍ដ៏ធំមួយប្រចាំឆ្នាំដើម្បីតាំងបង្ហាញផលិតផលដែលមានគុណភាពខ្ពស់របស់កម្ពុជាព្រមទាំងទំនិញនាំចេញ-នាំចូលសំខាន់ៗ និងសេវាកម្មដែលមានលក្ខណៈពិសេសរបស់បណ្តាអ្នកផ្គត់ផ្គង់ជុំវិញពិភពលោក។










លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបានមានប្រសាសន៍ថា ពិព័រណ៍ពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០២៥ រៀបចំឡើងស្របជាមួយនឹងការគាំទ្រផលិតផលខ្មែរពីសំណាក់ប្រជាពលរដ្ឋខ្មែរដោយមានដាក់តាំងបង្ហាញផលិតផលជាច្រើនរួមមានផលិតផលខ្មែរ និងផលិតផលសម្រាប់ការនាំចេញរបស់កម្ពុជា, ផលិតផលកម្មន្តសាល, ផលិតផលសិប្បកម្ម, ផលិតផលកសិកម្ម និងសេវាកម្មរួមជាមួយព្រឹត្តិការណ៍អមនានាបន្ថែមទៀតដូចជា ការតាំងបង្ហាញផលិតផលនិងលក់ទំនិញ, វេទិកាស្តីពីការការនាំចេញរបស់កម្ពុជា, កម្មវិធីជំនួបពាណិជ្ជកម្មស្តីពីការអភិវឌ្ឍទីផ្សារផលិតផលសក្តានុពលកម្ពុជា, វេទិកាប្រកួតប្រជែងសិស្សនិស្សិត និងការប្រគំតន្ត្រីផងដែរ។

ស្ថិតក្នុងឱកាសនេះដែរឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានប្រសាសន៍ថា ព្រឹត្តិការណ៍ពិព័រណ៍នេះមានភាពច្នៃប្រឌិត រស់រវើក និងសម្បូរបែប និងរៀបចំទាន់សភាពការណ៍បច្ចុប្បន្ន ហើយក៏ជាព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្មកម្រិតអន្តរជាតិដ៏ធំមួយប្រចាំឆ្នាំដែលរាជរដ្ឋាភិបាលកម្ពុជាដោយមានក្រសួងពាណិជ្ជកម្មជាសេនាធិការផ្តួចផ្តើមរៀបចំឡើងក្នុងគោលបំណងជំរុញលើកកម្ពស់ និងបង្ហាញផលិតផល និងសេវាកម្មសក្តានុពលរបស់កម្ពុជា, តភ្ជាប់ទីផ្សារក្នុងស្រុក, បង្កើតឱកាសក្នុងការផ្គូផ្គងរវាងធុរជនក្នុងស្រុក និងអន្តរជាតិ និងផ្សព្វផ្សាយពីកាលានុវត្តភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជា។

សូមបញ្ជាក់ថា ពិព័រណ៍នេះមានរយៈពេល៤ថ្ងៃពោលគឺចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ ដែលមានស្តង់តាំងបង្ហាញប្រមាណ ២៥០ស្តង់ដែលក្នុងនោះ ៦០% គឺជាផលិតផលខ្មែរបន្ថែមពីលើនេះក៏មានស្តង់ផលិតផលពីប្រទេសមួយចំនួនទៀតដូចជា ចិន ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងវៀតណាមផងដែរ។







# សមាគមឧកញ៉ាកម្ពុជា សហការជាមួយក្រុមហ៊ុន CANCAP GLOBALL រៀបចំកិច្ចពិភាក្សាតុមូលស្តីពី «ការវិនិយោគលើវិស័យកសិកម្ម ប្រព័ន្ធតាមដានសត្វចិញ្ចឹម និងឧស្សាហកម្មឈើកែច្នៃនៅកម្ពុជា» ដោយមានការគាំទ្រពីស្ថានទូតកាណាដាប្រចាំនៅកម្ពុជា



នាព្រឹកថ្ងៃព្រហស្បតិ៍ ទី៤ ខែធ្នូ ឆ្នាំ២០២៥ នាសណ្ឋាគារ ហៃយ៉ាត់ រីជិនសុី ភ្នំពេញ អ្នកឧកញ៉ា គួន ធីតា អនុប្រធាន តំណាងឱ្យលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំកិច្ចពិភាក្សាតុមូលស្តីពី "ការវិនិយោគលើវិស័យកសិកម្ម ប្រព័ន្ធតាមដានសត្វចិញ្ចឹម និងឧស្សាហកម្មឈើកែច្នៃនៅកម្ពុជា"ដោយមានការចូលរួមអមពីអ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងសមាជិកសមាគមឧកញ៉ាកម្ពុជាជាច្រើនរូប ព្រមទាំងមានការចូលរួមពី ឯកឧត្តម Christian DesRoches ឯកអគ្គរដ្ឋទូតកាណាដាប្រចាំព្រះរាជាណាចក្រកម្ពុជា, តំណាងអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, តំណាងស្ថាប័នវិនិយោគតំបន់កេបិកនៃប្រទេសកាណាដា, អ្នកជំនាញ និងធុរជន/វិនិយោគិនកម្ពុជា និងកាណាដាជាច្រើនរូប។

កិច្ចពិភាក្សាតុមូលនេះត្រូវបានរៀបចំឡើង ដើម្បីពិភាក្សានិងផ្លាស់ប្តូរយោបល់គ្នាពាក់ព័ន្ធនឹងការធ្វើធុរកិច្ចដោយប្រើបច្ចេកវិទ្យាក្នុងការចិញ្ចឹមសត្វ និងឧស្សាហកម្មឈើកែច្នៃ ក្នុងគោលបំណងចូលរួមជំរុញតម្លាភាពខ្សែច្រវាក់តម្លៃនៃការចិញ្ចឹមសត្វ និងឧស្សាហកម្មឈើកែច្នៃ ការជ្រៀតចូលទៅកាន់ទីផ្សារ និងការកសាងភាពធន់ក្នុងវិស័យទាំងនេះ តាមរយៈការកសាងសមត្ថភាព និងផ្តល់ដំណោះស្រាយតាមបច្ចេកវិទ្យាទំនើប រួមចំណែកដល់ការលើកកម្ពស់វិស័យកសិកម្មនៅកម្ពុជា។

ជាកិច្ចចាប់ផ្តើម អ្នកឧកញ៉ា គួន ធីតា បានថ្លែងសុន្ទរកថាស្វាគមន៍ដល់អង្គប្រជុំទាំងមូល និងបានលើកឡើងអំពីទិដ្ឋភាពទូទៅនៃវិស័យកសិកម្ម ដែលជាវិស័យស្នូលមួយដ៏សំខាន់រួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ ក្នុងនោះការចិញ្ចឹមសត្វ និងឧស្សាហកម្មកែច្នៃឈើក៏កំពុងមានការអភិវឌ្ឍ ប៉ុន្តែនៅក្នុងកម្រិតមួយទាបនៅឡើយ ដែលត្រូវការកិច្ចសហការ ការគាំទ្រ និងបច្ចេកវិទ្យាទំនើបមកជំរុញវិស័យទាំងនេះឱ្យកាន់តែល្អប្រសើរ តួយ៉ាងកិច្ចពិភាក្សាថ្ងៃនេះនឹងមានការធ្វើបទបង្ហាញអំពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបដែលបង្ហាញដោយវាគ្មិនជំនាញពីកាដាណាផងដែរ។

បន្ថែមលើនេះ អ្នកឧកញ៉ា ហ៊ុន ឡាក់ ក៏បានជម្រាបជូនជាសង្ខេបដល់អង្គប្រជុំអំពីសារៈតារ តួនាទីភារកិច្ចស្នូល និងសកម្មភាពសំខាន់ៗ របស់សមាគមឧកញ៉ាកម្ពុជា ដែលជាស្ថាប័នតែមួយគត់តំណាងឱ្យគោរមវន្តឧកញ៉ាទាំងអស់នៅកម្ពុជា និងមានសមាជិកប្រកបដោយសក្តានុពលជាបណ្តុំធុរជននិងវិនិយោគិនធ្វើការវិនិយោគលើចម្រុះវិស័យ។

ថ្លែងក្នុងកិច្ចពិភាក្សានេះ ឯកឧត្តមឯកអគ្គរដ្ឋទូត បានថ្លែងអំណរគុណចំពោះកិច្ចប្រឹងប្រែងក្នុងការរៀបចំឱ្យមានកិច្ចប្រជុំនេះឡើង ដែលជាវេទិកាមួយនឹងជួយជំរុញដល់ការស្វែងយល់ឱ្យកាន់តែស៊ីជម្រៅអំពីអ្វីដែលជាតម្រូវការជាក់ស្តែងរវាងធុរជនកម្ពុជានិងកាណាដាក្នុងការធ្វើទំនាក់ទំនងធុរកិច្ច និងវិនិយោគរួមគ្នា។ ក្នុងនាមឯកឧត្តមមានតួនាទីលើកកម្ពស់ទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ឯកឧត្តមសុំលើកទឹកចិត្ត និងផ្តល់គាំទ្រពេញទំហឹងដល់ធុរជននិងវិនិយោគិននៃប្រទេសទាំងពីរ សម្រាប់កិច្ចសហការធុរកិច្ចនានា ជាពិសេសលើគម្រោងធុរកិច្ចក្នុងវិស័យខាងលើនេះឱ្យលេចចេញជារូបរាងឡើង។

សូមជម្រាបផងដែរថា កិច្ចពិភាក្សាតុមូលនេះត្រូវបានសហការរៀបចំឡើងដោយសមាគមឧកញ៉ាកម្ពុជា និងក្រុមហ៊ុន CANCAP GLOBAL ដោយមានការគាំទ្រពីស្ថានទូតកាណាដាប្រចាំព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុន Référence Systèmes (Québec, Canada)។ ការរៀបចំកិច្ចប្រជុំនេះឆ្លុះបង្ហាញឱ្យឃើញអំពីឆន្ទៈរវាងភាគីកម្ពុជានិងកាណាដា ក្នុងការបន្តរក្សាទំនាក់ទំនង និងការផ្លាស់ប្តូរសកម្មភាពពាណិជ្ជកម្មទៅវិញទៅមកឱ្យកាន់តែសកម្មថែមទៀត បន្ទាប់ពីមានដំណើរទស្សនកិច្ចធុរកិច្ចក្រៅប្រទេសរបស់គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ក្នុងការចូលរួមអមដំណើរឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុង "បេសកកម្មទាក់ទាញនិងជំរុញវិនិយោគ" នៅប្រទេសកាណាដា កាលពីថ្ងៃទី២២ ខែកញ្ញា ដល់ថ្ងៃទី២ ខែតុលា ឆ្នាំ២០២៤ និងពីថ្ងៃទី២៧ ខែតុលា ដល់ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៥ នា ពេលកន្លងមក។ លើសពីនេះ ក្នុងឱកាសដែលកម្ពុជាជាម្ចាស់ផ្ទះត្រៀមរៀបចំ "កិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ ឆ្នាំ២០២៦ " នាពេលខាងមុខនេះ សមាគមឧកញ៉ាកម្ពុជា គ្រោងនឹងសហការជាមួយស្ថាប័ន Excellence Industrielle Siant-Laurent ដើម្បីរៀបចំជំនួបផ្គូផ្គងធុរកិច្ចដើម្បីផ្តល់ឱកាសដល់ធុរជន/វិនិយោគិនកម្ពុជា និងកាណាដាក្នុងការស្វែងយល់គ្នា និងទាញយកផលប្រយោជន៍ធុរកិច្ចផងដែរ។


















Roundtable Discussion on
04 December 2025


Roundtable Discussion on
04 December 2025





















# ឧកញ៉ាបណ្ឌិត លី រិទ្ធ សមាជិកក្រុមប្រឹក្សាភិបាល នៃសមាគមឧកញ៉ាកម្ពុជា ចូលរួមកម្មវិធី «បទបង្ហាញផ្នែកឯកជនស្តីពីកម្មវិធីអភិវឌ្ឍន៍បរិវត្តកម្មឌីជីថល និងបញ្ញាសិប្បនិម្មិតកម្ពុជា ឆ្នាំ២០២៦»

នាព្រឹកថ្ងៃអង្គារ ទី៩ ខែធ្នូ ឆ្នាំ២០២៥ ឧកញ៉ាបណ្ឌិត លី រិទ្ធ សមាជិកក្រុមប្រឹក្សាភិបាល តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានចូលរួមក្នុងកម្មវិធី “បទបង្ហាញផ្នែកឯកជនស្តីពីកម្មវិធីអភិវឌ្ឍន៍បរិវត្តកម្មឌីជីថល និងបញ្ញាសិប្បនិមិត្តកម្ពុជា ឆ្នាំ២០២៦” ដែលប្រព្រឹត្តនៅអគារ GDT Tower ដោយមានការចូលរួមពីតំណាងស្ថាប័នរដ្ឋ-ឯកជន វិទ្យាស្ថាន សមាគម សភាពាណិជ្ជកម្ម និងវាគ្មិនជាតិ និងអន្តរជាតិជាច្រើនរូប។

កិច្ចប្រជុំនេះត្រូវបានរៀបចំដោយ Enterpreneur Network Hub (EREB) Cambodia ដោយមានកិច្ចសហការជាមួយស្ថាប័នដៃគូជាតិ និងអន្តរជាតិ ដោយផ្តោតលើការពិភាក្សាអំពីដំណោះស្រាយក្នុងការគ្រប់គ្រងសាធារណៈ និងសហគ្រាសឯកជន ដោយប្រើប្រាស់បញ្ញាសិប្បនិមិត្តក្នុងការលើកកម្ពស់ប្រសិទ្ធភាព និងការផ្តល់សេវាសាធារណៈ, ការគាំទ្រដល់តម្លាភាព និងការសម្រេចចិត្តផ្អែកតាមទិន្នន័យ, ការពង្រឹងការអនុវត្តមានភាពប្រកួតប្រជែងរបស់សហគ្រាស, និងការរួមចំណែកក្នុងការអភិវឌ្ឍឌីជីថលជាតិក្នុងរយៈពេលវែង។ លើសពីនេះ កិច្ចប្រជុំនេះក៏បង្ហាញអំពីលទ្ធភាពនៃការវិនិយោគក្នុងគម្រោង តាមរយៈមូលនិធិឌីជីថលនីយកម្ម ដែលមានការគាំទ្រពីរដ្ឋាភិបាល និងនវានុវត្តន៍វិស័យឯកជនផងដែរ។















# អ្នកឧកញ៉ា គួន ធីតា អនុប្រធានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីប្រកួតវគ្គផ្តាច់ព្រ័ត្រ និងបិទវគ្គបណ្តុះបណ្តាលយុវជនក្រោមប្រធានបទ «ជំរុញអានុភាពអនាគតសហគ្រិន» ក្រោមអធិបតីភាព ឯកឧត្តមបនាយករដ្ឋមន្ត្រី ហ៊ុន ម៉ានី














នាថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥ អ្នកឧកញ៉ា គួន ធីតា អនុប្រធាន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយអ្នកឧកញ៉ា ឧកញ៉ា ជាច្រើនរូបទៀតបានចូលរួមពិធីប្រកួតវគ្គផ្តាច់ព្រ័ត្រ និងបិទវគ្គបណ្តុះបណ្តាលយុវជនក្រោមប្រធានបទ « ជំរុញអានុភាពអនាគតសហគ្រិន -Empowering Tomorrow's Entrepreneurs» ដែលបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឧបនាយករដ្ឋមន្ត្រី ឯកឧត្តម ហ៊ុន ម៉ានី ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា នាមជ្ឈមណ្ឌលសហប្រតិបត្តិកម្ពុជា-ជប៉ុន(CJCC) ។

សូមបញ្ជាក់ថាវគ្គបណ្តុះបណ្តាលនេះគឺជាគំនិតផ្តួចផ្តើមរបស់ឯកឧត្តម ហ៊ុន ម៉ានី ក្នុងគោលបំណងឱ្យយុវជនចូលរួមវគ្គបណ្តុះបណ្តាល និងហ្វឹកហាត់ជំនាញទន់ដែលចាំបាច់ក្នុងការចូលរួមចំណែកដល់សង្គមជាតិតាមរយៈការទទួលបាន ចំណេះដឹង មិត្តភាព បទពិសោធថ្មីៗ និងជាពិសេសបានរៀបចំផែនអាជីវកម្មរបស់ខ្លួនផងដែរ។

# អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ នៃសមាគមឧកញ៉ាកម្ពុជា និងសហការី ចូលរួមជំនួបផ្គូផ្គងធុរកិច្ចរវាងសមាគមឧកញ៉ាកម្ពុជា និងស្ថាប័ន Asia Pacific (TOP Excellence) Committee (APC)

នាព្រឹកថ្ងៃសៅរ៍ ទី១៣ ខែធ្នូ ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ រួមជាមួយអ្នកឧកញ៉ា និងឧកញ៉ាជាច្រើនរូបទៀតពីសមាគមឧកញ៉ាកម្ពុជាបានចូលរួមក្នុងជំនួបផ្គូផ្គងធុរកិច្ចរវាងសមាគមឧកញ៉ាកម្ពុជា និងស្ថាប័ន Asia Pacific (TOP Excellence) Committee (APC) ដែលបានប្រព្រឹត្តទៅនៅអគារ Picasso City Garden រាជធានីភ្នំពេញ។

ជាកិច្ចចាប់ផ្តើមតំណាងស្ថាប័ន APC បានធ្វើកិច្ចស្វាគមន៍ និងធ្វើបទបង្ហាញពាក់ព័ន្ធលើវិស័យ ហិរញ្ញវត្ថុ វិនិយោគ ថាមពលសូឡា សំណង់ ឧស្សាហកម្ម ក៏ដូចជាវិស័យផ្សព្វផ្សាយ និងព័ត៌មានជាដើម។

ជាមួយគ្នានេះ អ្នកឧកញ៉ា ហ៊ុន ឡាក់ ក៏បានធ្វើបទបង្ហាញសង្ខេបអំពីសាវតា នៃសមាគមឧកញ៉ាកម្ពុជា ដែលជាស្ថាប័នឯកជនប្រមូលផ្តុំដោយធុរជនដែលកំពុងវិនិយោគលើពហុវិស័យនិងបានរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិក៏ដូចជាបានបង្កើតការងាររាប់សែនកន្លែងជូនប្រជាពលរដ្ឋខ្មែរនៅទូទាំងប្រទេស។

បន្ថែមពីលើនេះ អ្នកឧកញ៉ាអគ្គលេខាធិការបានសង្កត់ធ្ងន់ថា សមាគមឧកញ៉ាកម្ពុជា សូមស្វាគមន៍នូវកិច្ចសហប្រតិបត្តិការធុរកិច្ចរវាងស្ថាប័នទាំងពីរ ព្រមទាំងរីករាយក្នុងការសហការ និងជួយសម្របសម្រួលរាល់សកម្មភាពស្វែងរកដៃគូវិនិយោគរបស់ស្ថាប័ន APC នៅកម្ពុជា ក្នុងគោលបំណងទាក់ទាញវិនិយោគិនចិនបន្ថែមទៀតដើម្បីឈានទៅរកការបង្កើតកាលានុវត្តភាពនៃការចាប់ដៃគូធុរកិច្ច និងពាណិជ្ជកម្មរវាងសមាជិករបស់ស្ថាប័នទាំងពីរនាពេលអនាគត ជាពិសេសជំរុញការវិនិយោគលើវិស័យដែលមានសក្តានុពលតែម្តង។



















# អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ទទួលជួបសំណេះសំណាល និងពិភាក្សាធុរកិច្ចជាមួយគណៈប្រតិភូធុរកិច្ចឥណ្ឌា នៃសហព័ន្ធអង្គការអ្នកនាំចេញឥណ្ឌា (FIEO)




នាថ្ងៃពុធ ទី១៧ ខែធ្នូ ឆ្នាំ២០២៥ នាសណ្ឋាគារ Fairfield Marriot ភ្នំពេញ, អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ទទួលជួបសំណេះសំណាល និងពិភាក្សាធុរកិច្ចជាមួយគណៈប្រតិភូធុរកិច្ចឥណ្ឌានៃសហព័ន្ធអង្គការអ្នកនាំចេញឥណ្ឌា (Federation of Indian Export Organization - FIEO) ដឹកនាំដោយលោក Suvidh Shah អគ្គនាយកនៃសហព័ន្ធ FIEO ដោយមានការចូលរួមជាអធិបតីពីលោកស្រីបណ្ឌិត Tanu Priya លេខាធិការទី១ ផ្នែកនយោបាយ និងសេដ្ឋកិច្ច នៃស្ថានទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា។

ជាកិច្ចចាប់ផ្តើម អ្នកឧកញ៉ាអគ្គលេខាធិការ បានសម្តែងកិច្ចស្វាគមន៍ចំពោះគណៈប្រតិភូឥណ្ឌាដែលអញ្ជើញបំពេញទស្សនកិច្ចធុរកិច្ចនៅកម្ពុជា និងចំណាយពេលវេលាដ៏មានតម្លៃជួបជាមួយសមាគមឧកញ៉ាកម្ពុជាដែលនេះជាជំនួបលើកដំបូងរវាងស្ថាប័នទាំងពីរ និងជាកិច្ចចាប់ផ្តើមក្នុងការកសាងនូវទំនាក់ទំនងពាណិជ្ជកម្មជាមួយគ្នាទៅវិញទៅមក។ អ្នកឧកញ៉ាបានជម្រាបជូនគណៈប្រតិភូឥណ្ឌាអំពីសារតារ តួនាទីភារកិច្ចស្នូល និងសកម្មភាពសំខាន់ៗរបស់សមាគមដែលជាស្ថាប័នតែមួយគត់តំណាងឱ្យគោរមវន្តឧកញ៉ាទាំងអស់នៅកម្ពុជា និងជាបណ្តុំធុរជននិងវិនិយោគិនមានអាជីវកម្មលើពហុវិស័យនៅកម្ពុជា និងមានសក្តានុពលក្នុងការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ ជាពិសេសឥណ្ឌាដែលជាទីផ្សារដ៏ធំមួយជាមួយសេដ្ឋកិច្ចលូតលាស់លឿនបំផុតក្នុងពិភពលោក។

ជាកិច្ចឆ្លើយតបលោក Suvidh Shah បានថ្លែងអំណរគុណដល់សមាគមឧកញ៉ាកម្ពុជា ដែលបានអនុញ្ញាតឱ្យរូបលោក និងគណៈប្រតិភូឥណ្ឌាបានចូលជួបសម្តែងការគួរសម និងពិភាក្សាធុរកិច្ចដោយលោកមានសុទិដ្ឋិនិយមថា នេះជាជំហានដ៏វិជ្ជមានក្នុងការពង្រីកទីផ្សារផលិតផលឥណ្ឌាមកកាន់កម្ពុជា តាមរយៈកិច្ចសហការធុរកិច្ចជាមួយធុរជនកម្ពុជា ជាពិសេសជាមួយការគាំទ្រពីសមាគមឧកញ៉ាកម្ពុជាផងដែរ។ លោក Suvidh Shah បានជម្រាបបន្ថែមថា សមាសភាពគណៈប្រតិភូឥណ្ឌាដែលមានវត្តមាននាថ្ងៃនេះ គឺសុទ្ធសឹងតែជាធុរជនជាអ្នកនាំចេញ-នាំចូល មានទស្សនវិស័យ និងសក្តានុពលមកពីវិស័យសំខាន់ៗ ដូចជា សម្ភារៈសំណង់និងឧស្សាហកម្ម, ឧបករណ៍វិទ្យាសាស្ត្រ និងស្តង់ទិន្នន័យ, ប្រព័ន្ធបូមទឹក, គីមីនិងឧស្ម័នក្នុងឧស្សាហកម្ម, ស្បែក វាយនភណ្ឌ និងសម្ភារៈកាត់ដេរ, ការថែទាំសុខភាពនិងឱសថ, សេវាជ្រើសរើសបុគ្គលិក និងធនធានមនុស្ស, គ្រឿងសង្ហារិម និងបរិក្ខារក្នុងផ្ទះ។

ក្នុងឱកាសនេះដែរ គណៈប្រតិភូនៃស្ថាប័នទាំងពីរបានធ្វើបទបង្ហាញអំពីសមាសភាព និងអាជីវកម្មរបស់ខ្លួនទៅវិញទៅមក ដើម្បីងាយស្រួលក្នុងការផ្គូផ្គងពាណិជ្ជកម្មនិងការចាប់ដៃគូជាមួយគ្នា ក្នុងវិស័យអាទិភាពរៀងៗខ្លួន សម្រាប់កិច្ចសហការធុរកិច្ចនាពេលអនាគត។

























# អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួម «ជំនួបផ្គូផ្គងធុរកិច្ចកម្ពុជា-ឥណ្ឌា»

នាថ្ងៃពុធ ទី១៧ ខែធ្នូ ឆ្នាំ២០២៥ នាសណ្ឋាគារ Fairfield Marriot ភ្នំពេញ, អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ តំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំសមាជិកចូលរួម "ជំនួបផ្គូផ្គងធុរកិច្ចកម្ពុជា-ឥណ្ឌា" ដែលបានប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម Vanlalvawna Bawitlung ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា ដោយមានការចូលរួមពីតំណាងក្រសួង-ស្ថាប័នរដ្ឋ សភាពាណិជ្ជកម្ម សមាគម វិស័យឯកជន និងភាគីពាក់ព័ន្ធជាច្រើនរូបមកពីប្រទេសទាំងពីរ។

ជំនួបនេះត្រូវបានរៀបចំឡើង ដើម្បីជំរុញឱ្យមានការភ្ជាប់ទំនាក់ទំនងគ្នារវាងធុរជនឥណ្ឌាជាអ្នកនាំចេញ-នាំចូល, ធុរជនកម្ពុជា និងអ្នករៀបចំគោលនយោបាយ ក្នុងគោលបំណងសិក្សាស្វែងយល់បរិយាកាសធុរកិច្ច និងវិនិយោគនៅកម្ពុជា ក៏ដូចជា ពង្រីកកាលានុវត្តភាពសម្រាប់ការធ្វើពាណិជ្ជកម្មទ្វេភាគីលើចម្រុះវិស័យសំខាន់ៗរវាងប្រទេសទាំងពីរ។ លើសពីនេះ ជំនួបនេះក៏ជាវេទិកាក្នុងការកសាងបណ្តាញ និងការផ្គូផ្គងធុរកិច្ចរវាងធុរជនកម្ពុជា និងឥណ្ឌា សម្រាប់កិច្ចសហការក្នុងភាពជាដៃគូធុរកិច្ចក្នុងវិស័យអាទិភាពរៀងៗខ្លួនផងដែរ។

សូមជម្រាបផងដែរថា ព្រឹត្តិការណ៍ធុរកិច្ចនេះត្រូវបានរៀបចំឡើងដោយសហព័ន្ធអង្គការអ្នកនាំចេញឥណ្ឌា (Federation of Indian Export Organization - FIEO) ដោយមានការគាំទ្រពីស្ថានទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលក្នុងនោះ សហព័ន្ធ FIEO បានដឹកនាំគណៈប្រតិភូឥណ្ឌាចំនួន ១១ក្រុមហ៊ុនស្វែងរកដៃគូធុរកិច្ច និងវិនិយោគិននៅកម្ពុជាក្នុងវិស័យមានសក្តានុពល ដូចជា សម្ភារៈសំណង់និងឧស្សាហកម្ម, ឧបករណ៍វិទ្យាសាស្ត្រ និងស្តង់ទិន្នន័យ, ប្រព័ន្ធបូមទឹក, គីមីនិងឧស្ម័នក្នុងឧស្សាហកម្ម, ស្បែក វាយនភណ្ឌ និងសម្ភារៈកាត់ដេរ, ការថែទាំសុខភាពនិងឱសថ, សេវាជ្រើសរើសបុគ្គលិក និងធនធានមនុស្ស, គ្រឿងសង្ហារិម និងបរិក្ខារក្នុងផ្ទះ។













AMBODIA












## ថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា បំពេញដំណើរទស្សនកិច្ចស្វែងយល់អំពីការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈនៅវិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម (ITI)



ដោយមានការគាំទ្រពីសមាគមឧកញ៉ាកម្ពុជា និងកិច្ចសហការជាមួយវិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម (ITI) នាព្រឹកថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥ ឧកញ៉ា អាន ឌីណា សមាជិកសមាគមឧកញ៉ាកម្ពុជា និងជាអគ្គនាយកក្រុមហ៊ុន អេហ្វអេសស៊ី ខេអេច ខូអិលធីឌី បានរៀបចំដំណើរទស្សនកិច្ចសិក្សាស្វែងយល់អំពីការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ នៅវិទ្យាស្ថានបច្ចេកទេសឧស្សាហកម្មដោយមានការចូលរួមពីសំណាក់ឧកញ៉ា កែវ បូណ៌ភិរក្ស, ឧកញ៉ា តាំង ធា, ឧកញ៉ា ឈឹម បញ្ញា, ឧកញ៉ា ប៊ុន ណារី, ឧកញ៉ាបណ្ឌិត លី រិទ្ធ និងឧកញ៉ា សាយ សោភា ព្រមទាំងឧកញ៉ា តាំង ជូលី ប្រធានក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានបច្ចេកវិទ្យា និងកសិកម្មកម្ពុជា (CITA) ផងដែរ។

ជាកិច្ចចាប់ផ្តើម លោក ជិន តារ៉ា នាយកវិទ្យាស្ថាន ITI បានមានប្រសាសន៍ស្វាគមន៍ចំពោះវត្តមានរបស់ឧកញ៉ាទាំងអស់ដែលសុទ្ធសឹងជាសមាជិកនៃសមាគមឧកញ៉ាកម្ពុជាដែលបានបំពេញទស្សនកិច្ចនាថ្ងៃនេះដើម្បីស្វែងយល់អំពីរចនាសម្ព័ន្ធ ទស្សនវិស័យ ក៏ដូចជាបេសកកម្មរបស់ ITI ដែលជាគ្រឹះស្ថានសិក្សាស្ថិតក្រោមអភិបាលកិច្ចរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈលើជំនាញ ព័ត៌មានវិទ្យា បរិក្ខារត្រជាក់ វិស្វកម្មរថយន្ត វិស្វកម្មអគ្គិសនី មេកានិកឧស្សាហកម្ម វិស្វកម្មលោហៈបន្ទះបន្សារ និងជំនាញជាច្រើនទៀតស្របតាមកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ១លាន៥សែននាក់ដែលជាកម្មវិធីពិសេសមួយរបស់រាជរដ្ឋាភិបាលអាណត្តិទី៧ ក្នុងការកៀរគរយុវជនដែលបានបោះបង់ការសិក្សាកន្លងមក និងយុវជនដែលពុំមានជំនាញឱ្យចូលរៀនជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដើម្បីឱ្យពួកគេមានជំនាញមួយសម្រាប់ជីវិត។

ក្នុងឱកាសនេះដែរ ឧកញ៉ា អាន ឌីណា តំណាងសមាគមឧកញ៉ាកម្ពុជា បានថ្លែងថា តាមរយៈជំនួប និងដំណើរទស្សនកិច្ចសិក្សានៅថ្ងៃនេះពិតជាមានសារៈសំខាន់ក្នុងការសិក្សាស្វែងយល់ និងទទួលបានព័ត៌មាននានាអំពី ITI លើការបណ្តុះបណ្តាលជំនាញដល់យុវជនដែលជាកម្លាំងពលកម្មសកម្មសម្រាប់ប្រទេសជាតិ និងជាពិសេសគឺជាឱកាសដែលសមាជិកសមាគមឧកញ៉ាកម្ពុជា ដែលសុទ្ធសឹងជាធុរជនមកពីពហុវិស័យដូចជា ឧស្សាហកម្ម អចលនទ្រព្យ សំណង់ និងហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម បច្ចេកវិទ្យា។ល។ បានពិភាក្សា ក៏ដូចជាចែករំលែកនូវតម្រូវការផ្នែកធនធានមនុស្សរបស់អាជីវកម្មនីមួយៗដល់វិទ្យាស្ថានដើម្បីមានភាពងាយស្រួលក្នុងការតម្រង់ទិសដៅលើការបណ្តុះបណ្តាលឱ្យស្របគ្នាទៅនឹងតម្រូវការទីផ្សារនាពេលបច្ចុប្បន្នក៏ដូចជាអនាគតផងដែរ។

ឧកញ៉ាបានបន្ថែមថា ជំនួបនេះគឺជាការបើកផ្លូវដើម្បីឱ្យស្ថាប័នទាំងពីរបានស្វែងយល់ពីគ្នាទៅវិញទៅមក និងសង្ឃឹមយ៉ាងមុតមាំថានឹងមានជំនួបបែបនេះជាបន្តបន្ទាប់ទៀតដើម្បីបង្កើតកាលានុវត្តភាពក្នុងការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយគ្នាដែលនឹងផ្តល់អត្ថប្រយោជន៍ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ ខណៈដែលធុរជនជាច្រើនកំពុងយកចិត្តទុកដាក់ក្នុងការពង្រឹងគុណភាពផលិតផលក្នុងស្រុក។ ជាមួយគ្នានេះ ឧកញ៉ាក៏មានសុទិដ្ឋិនិយមថា កិច្ចសហការរវាងវិស័យឯកជន និងគ្រឹះស្ថានសិក្សារដ្ឋគឺជាកម្លាំងចលករដ៏សំខាន់ក្នុងការពង្រីកសក្តានុពលលើការបណ្តុះបណ្តាលជំនាញ និងបានបង្កើតការងារជូនប្រជាពលរដ្ឋខ្មែរកាន់តែច្រើនឡើងថែមទៀត។

បន្ទាប់មកទៀត គណៈប្រតិភូក៏បានធ្វើដំណើរទស្សនកិច្ចនៅតាមថ្នាក់រៀន និងរោងជាងក្នុងបរិវេណវិទ្យាស្ថានខណៈដែលសិស្សនិស្សិតកំពុងសិក្សា និងអនុវត្តផ្ទាល់តែម្តង។












# ឧកញ៉ាបណ្ឌិត តាន់ មុនីវណ្ណ សមាជិកក្រុមប្រឹក្សាភិបាល នៃសមាគមឧកញ៉ាកម្ពុជានិងសហការី ចូលរួមពិធីបើកសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍វាយតម្លៃលើការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា (ផ.អ.យ.អ.) ក្នុងឆ្នាំ២០២៣-២០២៤








នាព្រឹកថ្ងៃពុធ ទី២៤ ខែធ្នូ ឆ្នាំ២០២៥ ឧកញ៉ាបណ្ឌិត តាន់ មុនីវណ្ណ សមាជិកក្រុមប្រឹក្សាភិបាល បានដឹកនាំគណៈប្រតិភូ នៃសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីបើកសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍វាយតម្លៃលើការអនុវត្ត ផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា(ផ.អ.យ.អ.) ក្នុងឆ្នាំ២០២៣-២០២៤ ក្រោមអធិបតីភាព ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(ក.អ.ក.) ដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័ន និងតួអង្គពាក់ព័ន្ធជាច្រើនរូប។

សិក្ខាសាលានាព្រឹកនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងលើសពីការផ្សព្វផ្សាយរបាយការណ៍វាយតម្លៃលើការអនុវត្ត ផ.អ.យ.អ. ក្នុងរយៈពេលពីរឆ្នាំចុងក្រោយ (២០២៣-២០២៤) ប៉ុន្តែជាការលើកកម្ពស់ការជជែកពិភាក្សា ដើម្បីកំណត់ទិសដៅអភិវឌ្ឍន៍ និងកំណើននៃវិស័យអាទិភាពទាំងពីរនេះនាពេលខាងមុខ តាមរយៈកិច្ចពិភាក្សាដែលមានវាគ្មិនមកពីក្រសួង ស្ថាប័ន និងវិស័យឯកជនពាក់ព័ន្ធ លើប្រធានបទស្ដីពី "ការពង្រឹងកិច្ចសម្រួលពាណិជ្ជកម្ម និងការបង្កើនការនាំចេញក្នុងវិស័យយានយន្ត និងអេឡិចត្រូនិក"។ កិច្ចពិភាក្សានេះដែរ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីទទួលបានធាតុចូល និងអនុសាសន៍ចាំបាច់បន្ថែមទៀត ជាមូលដ្ឋានតម្រង់ទិសក្នុងការដាក់ចេញនូវវិធានការ និងយុទ្ធសាស្ត្រគន្លឹះថ្មីៗ សំដៅជំរុញការអភិវឌ្ឍវិស័យទាំងពីរ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា ព្រមទាំងពង្រីកភាពធន់នៃសេដ្ឋកិច្ចកម្ពុជា ឆ្លើយតបទៅនឹងការប្រែប្រួលឥតឈប់ឈរនៃស្ថានភាពសេដ្ឋកិច្ចសកល។


CDC















សមាគមឧកញ៉ាកម្ពុជា

## ទំនាក់ទំនងនិងទទួលព័ត៌មានអំពីយើងខ្ញុំតាមរយៈ

Telegram | Facebook | TikTok | Website | Youtube | X(Twitter)

ទីស្នាក់ការ សណ្ឋាគារភ្នំពេញ លេខ៥៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

(+៨៥៥) ២៣ ៨៦០ ៩៩៩ info@cambodianoknha.org www.cambodianoknha.org